បោះពុម្ពនៅរោងពុម្ព ទីស្តីការគណៈរដ្ឋមន្ត្រី
លើកទី១ ចំនួន ១.៥០០ ច្បាប់

តម្លៃ ២៧៥០ រៀល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
* * *

ឆ្នាំទី ៧ លេខ ៤៥-៤៦ ថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

# រាជកិច្ច

រួមមាន :

- ច្បាប់
- ក្រម-ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រី រៀងរាល់សប្តាហ៍

ក

# មាតិកា

## I- ខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


| | | |
|---|---|---|
| ៨-១២-១៩៩៩ | ព្រះរាជក្រឹត្យ នស/រកត/១២៩៩/២០៨ តែងតាំងលោក ឡោក ឃួរ ជាឧកញ៉ា | ២០៤៩ |
| ១៣-១២-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/១២៩៩/២០៩ តែងតាំងឯកឧត្តម ឆ្នាំ ម៉ុនស្រ៊ុន ជាទីប្រឹក្សាប្រធានរដ្ឋសភា | ២០៤៨ |
| ១៣-១២-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/១២៩៩/២១០ ផ្តល់សញ្ជាតិខ្មែរតាមសញ្ជាតូបនីយកម្ម ជូនកញ្ញា ហ្សេរ៉ាល់ឌីន ខុក្ស ( Géradine cox ) | ២០៤៩ |
| ១៤-១២-១៩៩៩ | - KRET NS/KRT/1299/211 Nommons Monsieur HEDI JAMA Conmandeur de ordre Royal dussahanéteri | ២០៥១ |
| ១៥-១២-១៩៩៩ | -ព្រះរាជក្រឹត្យ នស/រកត/១២៩៩/២១២ តែងតាំងឯកឧត្តម ឈឿង យ៉ាណាត់ ជាអគ្គលេខាធិការ នៃគណៈកម្មាធិការដឹកនាំការងារកម្មវិធីសិលេក | ២០៥២ |


## II-រាជរដ្ឋាភិបាល

### ១-អនុក្រឹត្យ


| | | |
|---|---|---|
| ០៣-១២-១៩៩៩ | -អនុក្រឹត្យលេខ ១០៧ អនក្រ.បក ស្តីពីការផ្ទេរឥណទាន | ២០៥៣ |
| ០៧-១២-១៩៩៩ | -អនុក្រឹត្យលេខ១០៨អនក្រ.បកស្តីពីការបន្ថែមសមាជិករបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងការបន្ថែម រចនាសម្ព័ន្ធនៃគណៈកម្មាធិការវិនិយោគកម្ពុជា | ២០៥៤ |
| ៨-១២-១៩៩៩ | -អនុក្រឹត្យលេខ ១០៩ អនក្រ.បក ស្តីពីការផ្ទេរឥណទាន | ២០៥៥ |
| ៩-១២-១៩៩៩ | -អនុក្រឹត្យលេខ ១១០ អនក្រ.បក ស្តីពីការបង្កើតស្ថានអគ្គកុងស៊ុល | ២០៥៧ |
| ១៤-១២-១៩៩៩ | -អនុក្រឹត្យលេខ ១១១ អនក្រ.បក ស្តីពីការផ្ទេរឥណទាន | ២០៥៨ |
| ៩-១២-១៩៩៩ | -អនុក្រឹត្យលេខ ៥៥០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២០៥៩ |
| ៩-១២-១៩៩៩ | -អនុក្រឹត្យលេខ ៥៥១ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២០៦០ |
| ១៣-១២-១៩៩៩ | -អនុក្រឹត្យលេខ ៥៥២ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ | ២០៦១ |

១៣-១២-១៩៩៩ -អនុក្រឹត្យលេខ ៥៥៣ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២០៦១
១៣-១២-១៩៩៩ -អនុក្រឹត្យលេខ ៥៥៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២០៦៣
១៤-១២-១៩៩៩ -អនុក្រឹត្យលេខ ៥៥៥ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ២០៦៤
១៤-១២-១៩៩៩ -អនុក្រឹត្យលេខ ៥៥៦ អនក្រ.តត ស្តីពីការជូនមេដាយគុណូបការជាតិ ២០៦៤

## ២-សេចក្តីសំរេច

៦-១២-១៩៩៩ -សេចក្តីសំរេចលេខ ៨១ សសរ ស្តីពីការបង្កើតគណៈបញ្ជាការត្រួតពិនិត្យប៉ះផ្លាញ និងទប់ស្កាត់ ការចរាចរការប្រើប្រាស់ និងការដាំដុះដំណាំគ្រឿងញៀន ២០៦៥
៨-១២-១៩៩៩ -សេចក្តីសំរេចលេខ ៨២ សសរ ស្តីពីការបង្កើតគណៈកម្មការកណ្តាលរៀបចំ កីឡាវាយកូនឃ្លីលើតុ ដណ្តើមពានរង្វាន់ ពិភពលោក ផ្នែកនារី ២០៦៧
៩-១២-១៩៩៩ -សេចក្តីសំរេចលេខ ៨៣ សសរ ស្តីពីការកែសម្រួលសមាសភាព នៃគណៈបញ្ជាការត្រួតពិនិត្យប៉ះផ្លាញ និងទប់ស្កាត់ការចរាចរ ការផលិត ការប្រើប្រាស់ និងការដាំដុះដំណាំគ្រឿងញៀន ២០៦៨

## ៣-សារាចរ

៦-១២-១៩៩៩ -សារាចរលេខ ១០ សរ ស្តីពីគោលការណ៍ នៃទំនាក់ទំនងជាមួយបរទេស ២០៧០

# III- ការងារបណ្តាក្រសួង

## ១-ទីស្តីការគណៈរដ្ឋមន្ត្រី

### សេចក្តីសំរេច

១៤-១២-១៩៩៩ -សេចក្តីសំរេចលេខ ៤៩ សសរ ស្តីពីការបង្កើតលេខាធិការដ្ឋាន នៃចំណុចការងារ សំរាប់តាមដានរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ២០៧២

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### សារាចរ

១៧-១២-១៩៩៩ -សារាចរលេខ ០១៧ សរណ.សហវ.ពដ ណែនាំស្តីពីការអនុវត្តន៍ពន្ធលើដីមិនបានប្រើប្រាស់ ២០៧៤

## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និងថាមពល

### ប្រកាស


| | | |
|---|---|---|
| ៣-១២-១៩៩៩ | -ប្រកាសលេខ ៩៦៥ ឧក.ប្រក អនុញ្ញាតឲ្យក្រុមហ៊ុនអូសេវិនធើ ហ្គាមេន មេនូហ្វេកឃើររីង ( ខេមបូឌា ) លីមីធីត តំណាងដោយលោក HUI CHONG WAI MORLEY សញ្ញាតិអង់គ្លេស បង្កើតរោងចក្រកាត់ដេរសំលៀកបំពាក់នាំចេញ | ២០៩២ |


## ៤-ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### ប្រកាស


| | | |
|---|---|---|
| ១៣-១២-១៩៩៩ | -ប្រកាសលេខ ២៦១២ អយក.ប្រក ស្តីពីការបើកអនុវិទ្យាល័យ អូរបែកក្អម ជាឧបសម្ព័ន្ធអនុវិទ្យាល័យទឹកល្អក់ ស្ថិតនៅក្នុងសង្កាត់ អូរបែកក្អម ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ | ២០៩៤ |
| ៦-១២-១៩៩៩ | -សេចក្តីសំរេចលេខ ០៧ អយក.សសរ ស្តីពីការទទួលស្គាល់សញ្ញាប័ត្ររបស់មណ្ឌលសិក្សាបច្ចេកទេសធនាគារ | ២០៩៥ |


## ៥-ទីស្តីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

### ប្រកាស


| | | |
|---|---|---|
| ១៥-១២-១៩៩៩ | -ប្រកាសលេខ ២៦២ បទ.ប្រក ស្តីពីការរៀបចំរចនាសម្ព័ន្ធគ្រប់គ្រង នៃប្រកាសលេខ ១៩០ បទ.ប្រក ចុះថ្ងៃទី១៧-៨-១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មន្ទីរ ប.ទ ខេត្ត-ក្រុង | ២០៩៦ |

# I- ខុទ្ទកាល័យព្រះមហាក្សត្រ

## ព្រះរាជក្រឹត្យ

ព្រះរាជក្រឹត្យ នស/រកត/១២៩៩/២០៨

យើង

ព្រះបាទសម្តេចព្រះនរោត្តម សីហនុ

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

តែងតាំង

លោក ឡោក ហ៊ីរ

ជា

ឧកញ៉ា

រាជធានីភ្នំពេញ, ថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

ព្រះរាជក្រឹត្យ នស/រកត/១២៩៩/២០៩

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

****

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

- យោងតាមសំណើរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ប្រធានរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសេចក្តីត្រូវការរាជការចាំបាច់

ត្រាស់បង្គាប់

មាត្រា ១ ._ តែងតាំងលោកឧត្តម ឆ្នាំ ម៉ុនស្រ៊ុន ជាទីប្រឹក្សាប្រធានរដ្ឋសភា ដែលមានឋានៈស្មើ រដ្ឋមន្ត្រី ។

មាត្រា ២ ._ ប្រធានរដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឲ្យបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ១...

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

ព្រះរាជក្រឹត្យ នស/រកត/១២៩៩/២១០

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី.

****

- បានទ្រង់ទតរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ទតព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់ទតព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់ទតព្រះរាជក្រមលេខ នស/រកម/០៩៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីសញ្ជាតិ
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៩៩

ត្រាស់បង្គាប់

មាត្រា ១ ._ ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ជូនកញ្ញា ហ្សេរ៉ាលឌីន ខុក្ស (Geraldine Cox) បច្ចុប្បន្នសញ្ជាតិអូស្ត្រាលី កើតនៅថ្ងៃទី ១០-៦-១៩៤៥ នៅប្រទេសអូស្ត្រាលី ។

មាត្រា ២ ._ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្ត ព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះព្រះហស្តលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ ១៩៩៩

ព្រះហស្តលេខា

នរោត្តម សីហនុ

★★★

# K R E T

**NS/KRT/1299/211**

Nous
Preah Bat Samdech
Preah Norodom Sihanouk
Reach Harivong Uphatosocheat Visotthipong
Akkamohaborosrath Nikarodom Thomika
Mohareacheathireach Boromneath Borombopit
Preah Chau Krong Kampuchea Thipadei,
Roi du Cambodge

MOMMONS

**Monsieur Hedi Jamai,**
**Commandeur de l'Ordre Royal du Sahamétrei,**
**en temoignage de Notre haute considération.**

**Signé**
**Norodom Sihanouk**

Fait au Palais Royal à Phnom Penh, le 14 Décembre 1999

★★★

# ព្រះរាជក្រឹត្យ នស/រកត/១២៩៩/២១២

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

****

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់អនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលោ
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ ._ ត្រូវបានតែងតាំងឯកឧត្តម ឈៀន យ៉ាំណាំង ជាអគ្គលេខាធិការ នៃគណៈកម្មាធិការដឹកនាំការងារ នៃកម្មវិធីសិលោ បន្ថែមលើភារកិច្ចបច្ចុប្បន្ន មានឋានៈស្មើ រដ្ឋលេខាធិការ ។

មាត្រា ២ ._ នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឲ្យបានសំរេច ។

មាត្រា ៣ ._ ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ ១៩៩៩

ព្រះហស្ថលេខា

នរោត្តម សីហនុ

★★★

# II- រាជរដ្ឋាភិបាល

## ១-អនុក្រឹត្យ

### អនុក្រឹត្យលេខ ១០៧ អនក្រ.បក
### ស្តីពីការផ្ទេរឥណទាន

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម នរ/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការផ្ទេរចំណូល និងផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### សំរេច

**មាត្រា ១ ._** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ២៥ លានរៀល ( ម្ភៃប្រាំលានរៀល ) ពីជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និង ការជួសជុលតូច ) មកជំពូក៣២ (អន្តរាគមន៍ក្នុងវិស័យអន្តរជាតិ វិភាគទានអោយអង្គការអន្តរជាតិនានា ) របស់ក្រសួងទេសចរណ៍សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩ ។

មាត្រា ២ ._ តំណាងគណៈកម្មការក្នុងមាត្រា១ ខាងលើត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់បង់វិភាគទានជូន សមាគម PATA ។

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ១៩៩៩

បានយកសេចក្តីជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា
ហត្ថលេខា
គាត ឈន់
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ១០៨ អនក្រ.បក
## ស្តីពីការបន្ថែមសមាជិករបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ការបន្ថែម លេខាសម្ព័ន្ធនៃគណៈកម្មាធិការវិនិយោគកម្ពុជា

***

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ស្តីពីការរៀបចំ និងការ ប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ ១៩៩៩ ស្តីពីការកែតំរូវទៅលើអនុក្រឹត្យលេខ៥១ អនក្រ.បក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- យោងសេចក្តីសំរេចរបស់សម័យប្រជុំពេញអង្គក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា នាថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៩
- យោងតាមសំណូមពរចាំបាច់លោះមុខ

សម្រេច

**មាត្រា ១ .-** ត្រូវបានបន្ថែមសមាសភាព **សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ឬ តំណាង** ជាសមាជិករបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងមាត្រា១ថ្មី នៃអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ១៩៩៩ ស្តីពីការកែតម្រូវទៅលើ អនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**មាត្រា ២ .-** ត្រូវបានបន្ថែម ផ្នែកត្រួតពិនិត្យ និង តាមដានគំរោងវិនិយោគ ក្នុងរចនាសម្ព័ន្ធ នៃគណៈកម្មាធិការវិនិយោគកម្ពុជាដែលមានចែងក្នុងមាត្រា៥ នៃអនុក្រឹត្យលេខ ៥១ អនក្រ.បក ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ១៩៩៥ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**មាត្រា ៣ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា គ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមអនុក្រឹត្យនេះអោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៧ ខែធ្នូ ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

បានជំរាបជូន
សម្តេចនាយករដ្ឋមន្ត្រី
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
និងជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
ហត្ថលេខា
**គាត ឈន់**

★★★

## អនុក្រឹត្យលេខ ១០៩ អនក្រ.បក
### ស្តីពីការផ្ទេរតំណែង

***

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម នស/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ ១៩៩៩ ស្ដីពីការបែងចែកឥណទានថវិកាលំអិតតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្ដីពីការផ្ទេរចំណូល និងផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី
- តាមសំណើរបស់ឯកឧត្ដមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

**សំរេច**

**មាត្រា ១** . ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៩៥៤ លានរៀល ( ប្រាំបួនរយហាសិបបួនលានរៀលគត់) ពីជំពូក ១១ ( ចំណាយទៅលើការរដ្ឋបាល សំភារៈ និង ការផ្គត់ផ្គង់ ) មកជំពូក១០ ( បៀវត្ស និង ប្រាក់បំណាច់ ) របស់ក្រសួងមហាផ្ទៃផ្នែកសន្តិសុខសាធារណៈ សំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩ ។

**មាត្រា ២** ._ ឥណទានថវិកាក្នុងមាត្រា១ ខាងលើត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ សំរាប់ទូទាត់បំណុលថ្លៃទិញអង្ករជូនក្រុមហ៊ុន ម៉ែន សារុន ។

**មាត្រា ៣** ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៩៩

បានយកសេចក្ដីជំរាបជូន
សម្ដេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា
ហត្ថលេខា
**គាត ឈន់**
ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

នាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
**ហ៊ុន សែន**

★★★

# អនុក្រឹត្យលេខ ១១០ អនក្រ.បក
## ស្តីពីការបង្កើតស្ថានអគ្គកុងស៊ុល

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម០១៩៦/១០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ
- តាមសំណើរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

## សំរេច

**មាត្រា ១ .**_ បង្កើតស្ថានអគ្គកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំស្រុកសារញ្ញ និង ប្រចាំស្រុកក្លងយ៉ៃ នៃព្រះរាជាណាចក្រថៃឡង់ ។

**មាត្រា ២ .**_ ស្ថានអគ្គកុងស៊ុលនីមួយៗ ត្រូវដឹកនាំដោយប្រធានបេសកកម្មកុងស៊ុលម្នាក់ ដែលមានឋានៈជាអគ្គកុងស៊ុល ។

**មាត្រា ៣ .**_ សមាសភាពមន្ត្រីកុងស៊ុលផ្សេងទៀត យ៉ាងច្រើនបំផុត ០២ នាក់ នឹងត្រូវកំណត់តាមសេចក្តីត្រូវការនៃកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជា ។ រីឯបុគ្គលិកមិនមែនកុងស៊ុលទាំងឡាយ នឹងត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

**មាត្រា ៤ .**_ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុករៀងៗខ្លួន អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ១១១ អនក្រ.បក
## ស្តីពីការផ្ទេរឥណទាន

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម ០១/នស/៩៣ ចុះថ្ងៃទី២៨ ខែ ធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រម នស/រកម/០១៩៩/០១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ ១៩៩៩ ស្តីពីការបែងចែកឥណទានថវិកាចំណាយតាមជំពូក នៃច្បាប់ហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រង ឆ្នាំ១៩៩៩
- បានឃើញអនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩៩ ស្តីពីការផ្ទេរចំណូល និងផ្ទេរឥណទានថវិកា សំរាប់ក្រសួងស្ថាប័នថ្មី
- តាមសំណើរបស់ឯកឧត្តមទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សំរេច

**មាត្រា ១ ._** ត្រូវបានអនុញ្ញាតអោយផ្ទេរឥណទានថវិកា ចំនួន ២៥០ លានរៀល ( ពីររយហាសិបលានរៀល ) ពីជំពូក ១០ ( បៀវត្ស និង ប្រាក់បំណាច់ ) មកជំពូក ១១ ( ចំណាយដំណើរការរដ្ឋបាល សំភារៈ និងការជួសជុលតូច ) របស់ព្រឹទ្ធសភាសំរាប់ការគ្រប់គ្រង ឆ្នាំ ១៩៩៩ ។

**មាត្រា ២ ._** ឥណទានថវិកាក្នុងមាត្រា១ ខាងលើត្រូវបានអនុញ្ញាតអោយប្រើប្រាស់ សំរាប់ចំណាយដំណើរការរដ្ឋបាល ដែលខ្វះក្នុង ឆ្នាំ១៩៩៩ ។

មាត្រា ៣ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គលេខាធិការព្រឹទ្ធសភា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យ នេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី ដើម្បីចុះហត្ថលេខា

ហត្ថលេខា

**គាត ឈន់**

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

★★★

## អនុក្រឹត្យលេខ ៥៥០ អនក្រ.តត

## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

### សំរេច

មាត្រា ១ ._ តែងតាំងលោក កែវ សីវម្មត្រ បច្ចុប្បន្នអនុប្រធាននាយកដ្ឋាននៃអគ្គនាយកដ្ឋានអាស៊ាន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាអគ្គកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំក្រុងអារញ្ញ នៃព្រះរាជាណាចក្រថៃឡង់ ។

មាត្រា ២ ._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈសហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យលេខ ៥៥១ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៨ ស្តីពីការបង្កើតខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា
- យោងតាមសំណូមពរការងារចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សំរេច

**មាត្រា ១ .** ត្រូវបានតែងតាំងជា សមាជិកក្រុមលេខាសម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជាដូចមានរាយនាមខាងក្រោម ៖

១-លោក **ឈរ ផល្លី** មានឋានៈស្មើ ប្រធាននាយកដ្ឋាន

២-កញ្ញា **ឈរ ស្រីពិន** មានឋានៈស្មើ ប្រធាននាយកដ្ឋាន ។

**មាត្រា ២ .** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៥៥២ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- តាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### សម្រេច

**មាត្រា ១ ._** តែងតាំងលោក ម៉ែន សារុម ជានាយកវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍ កសិកម្មកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ២ ._** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ តាំងពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៥៥៣ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កម្ពុជា ជាគ្រឹះស្ថានសាធារណរដ្ឋបាល
- តាមសំណើររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១ .-** ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល របស់វិទ្យាស្ថានស្រាវជ្រាវ និង អភិវឌ្ឍន៍កសិកម្មកម្ពុជា ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១-លោក | **ឈាន សំហាត** | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ | ប្រធាន |
| ២-លោក | **ខេព ទុន្ថា** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៣-លោក | **ចាប សុវណ្ណ** | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤-លោក | **ភាន់ វិបុល** | តំណាងក្រសួងបរិស្ថាន | សមាជិក |
| ៥-លោក | **អេង គីមលី** | តំណាងក្រសួងអប់រំយុវជន និងកីឡា | សមាជិក |
| ៦-លោក | **ទ្រី មេង** | តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៧-លោក | **ឡឹង សុធាច័ន្ទនី** | តំណាងក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ៨-លោក | **នុត សាខន** | តំណាងនាយកដ្ឋានក្សេត្រសាស្ត្រ | សមាជិក |
| ៩-លោក | **ម៉ែន សារុម** | នាយកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិក |
| ១០-លោក | **ហុង អុន** | ឥស្សរជនមានបទពិសោធន៍ផ្នែកកសិកម្ម | សមាជិក |
| ១១-លោក | **មាស ពិសិដ្ឋ** | តំណាងនិយោជិត | សមាជិកស្វ័យប្រវត្តិ |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

# អនុក្រឹត្យលេខ ៥៥៨ អនក្រ.តត
# ស្ដីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ ១៩៩៩ ស្ដីពីការបង្កើតក្រុមហ៊ុន សំភារៈកសិកម្ម
- តាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សំរេច

**មាត្រា ១ .-** ត្រូវបានតែងតាំងសមាសភាពក្រុមប្រឹក្សាភិបាល ប្រចាំក្រុមហ៊ុនសំភារៈកសិកម្ម ដែលជាសហគ្រាសសាធារណៈមានលក្ខណៈជាក្រុមហ៊ុនរដ្ឋ មាននាមដូចខាងក្រោម ៖

| | | |
|---|---|---|
| ១-លោក **លួន គឹមធឿ** | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២-លោក **ឌុច ហឿន** | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៣-លោក **អ៊ុំ សំផន** | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៤-លោក **ជ័យ សាវឿ** | អគ្គនាយក ក្រុមហ៊ុនសំភារៈកសិកម្ម | សមាជិក |
| ៥-លោក **ទ៉ាន់ ឆាន** | តំណាងនិយោជិតរបស់ ក.ហ.ស.ក | សមាជិកស្វ័យប្រវត្តិ |

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះ ហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែ ធ្នូ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

★★★

## អនុក្រឹត្យលេខ ៥៥៥ អនក្រ.តត
## ស្តីពីការតែងតាំងមន្ត្រីរាជការ

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៧០ អនក្រ.បក ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងព័ត៌មាន
- យោងតាមសំណើរបស់ក្រសួងព័ត៌មាន

### សម្រេច

មាត្រា ១._ តែងតាំងលោក គី ឡុង ជាប្រធាននាយកដ្ឋានព័ត៌មានក្នុង និង ក្រៅប្រទេស នៃអគ្គនាយកដ្ឋានទូរទស្សន៍ជាតិកម្ពុជា នៃក្រសួងព័ត៌មាន ។

មាត្រា ២. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងព័ត៌មាន រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលមានការពាក់ព័ន្ធ និងសាមីខ្លួនត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## អនុក្រឹត្យលេខ ៥៥៦ អនក្រ.តត
## ស្តីពីការជូនមេដាយស្ថាបនាជាតិ
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ចស/រកត/០១០៩៥/០១ ចុះថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៩៥ ស្ដីពីការប្រកាសឱ្យប្រើគ្រឿងឥស្សរិយយសនៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី

**សំរេច**

**មាត្រា ១**._ ត្រូវបានប្រគល់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក ATRICK VAN DE VELDE Coordinateur, Bureau de Coordination Technique de L'UNION EUROPEENNE ដែលបានបំពេញភារកិច្ចដោយស្មារតីទទួលខុសត្រូវ និងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការស្ដារ និងអភិវឌ្ឍន៍ ព្រះរាជាណាចក្រកម្ពុជា ឡើងវិញ ។

**មាត្រា ២**._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តសេចក្ដីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែ ធ្នូ ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## ២-សេចក្ដីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី០៦ ខែ ធ្នូ ឆ្នាំ ១៩៩៩

### សេចក្ដីសំរេចលេខ ៨១ សសរ

### ស្ដីពីការបង្កើតគណៈបញ្ជាការត្រួតពិនិត្យ បំផ្លាញ និងទប់ស្កាត់ ការចរាចរ ការផលិត ការប្រើប្រាស់ និងការដាំដុះដំណាំគ្រឿងញៀន

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- តាមសំណើរបស់អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**សំរេច**

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មការត្រួតពិនិត្យ បង្ក្រាបនិងបញ្ចប់ការដាំដុះ ការផលិត ការប្រើប្រាស់ និងការជួញដូរគ្រឿងញៀនគ្រប់ប្រភេទ ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្ដមឧត្ដមសេនីយ៍ឯក ម៉ុល សាររឿន អគ្គមេបញ្ជាការរង ក.ភ.ម.ក ជាប្រធាន

២-ឯកឧត្ដមឧត្ដមសេនីយ៍ឯក សុះ ផន អគ្គនាយករងទី១នគរបាលជាតិ ជាអនុប្រធាន

៣-ឯកឧត្ដមឧត្ដមសេនីយ៍ទោ សារិទ្ធិ ឌី មេបញ្ជាការយោធភូមិភាគទី៣ សមាជិក

៤-ឯកឧត្ដម លី ស៊ូ អភិបាលខេត្តនិងជាប្រធានគណៈកម្មការសន្តិសុខខេត្តកំពត សមាជិក

៥-ឯកឧត្ដមឧត្ដមសេនីយ៍ត្រី ខៀវ សុគន់ អគ្គលេខាធិការរងនៃ អ.ជ.ប.គ.ញ សមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច និងសិទ្ធិដូចតទៅ :

-ត្រួតត្រានិងត្រួតពិនិត្យលើមានតំបន់ទីតាំងដាំដុះគ្រឿងញៀន (កញ្ឆា) ក្នុងភូមិសាស្ត្រខេត្តក្រុង ។

-ចាត់តាំងក្រុមស្រាវជ្រាវអង្កេត ស្រាវជ្រាវ និងដាក់ព័ត៌មានពាក់ព័ន្ធនឹងការដាំដុះជួញដូរកញ្ឆា ដើម្បីបញ្ជូនទៅតុលាការកាត់ក្ដីតាមច្បាប់ ។

-ធ្វើការផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋអំពីគ្រោះថ្នាក់នៃការប្រព្រឹត្តបទល្មើសដាំដុះ ផលិត ប្រើប្រាស់និងជួញដូរគ្រឿងញៀន ដោយខុសច្បាប់ ។

-មានសិទ្ធិបញ្ជា និងប្រើប្រាស់កំលាំងយោធារបស់យោធភូមិភាគទី៣ កំលាំងនគរបាលរបស់ស្នងការដ្ឋាននគរបាលខេត្តកំពតនិងកំលាំងកងរាជអាវុធហត្ថខេត្តកំពត ក្នុងការបំពេញភារកិច្ចរបស់ខ្លួន ។

-មានសិទ្ធិប្រើប្រាស់ត្រារបស់អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ ដើម្បីចេញលិខិតផ្លូវការផ្សេងៗ ។

ប្រការ ៣ : ប្រសិនបើខេត្ត ក្រុងណាផ្សេងមានករណីដូចខេត្តកំពត សមាសភាពនៃគណៈកម្មការនេះ ត្រូវប្ដូរមេបញ្ជាការយោធភូមិភាគនិងប្រធានគណៈកម្មការសន្តិសុខខេត្តនោះ បញ្ចូលជាសមាជិកនៃគណៈកម្មការ ។ រីឯសមាសភាពក្រៅពីនេះត្រូវរក្សាទុកដដែល ។

ប្រការ ៤ : ប្រធានគណៈកម្មការត្រូវរាយការណ៍ពីលទ្ធផល នៃកិច្ចប្រតិបត្តិការរបស់ខ្លួនជូនប្រមុខរាជរដ្ឋាភិបាលតាមពេលកំណត់ជាប្រចាំ ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿង

ញៀននិងឯកឧត្តមដែលមានឈ្មោះក្នុងប្រការមួយត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ដោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.នាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ស ខេង

★★★

រាជធានីភ្នំពេញ, ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ៨២ សសរ
## ស្តីពីការបង្កើតគណៈកម្មការកណ្តាលរៀបចំ
## កីឡាវាយកូនឃ្លីលើតុ ជណ្តើមពានរង្វាន់
## ពិភពលោក ផ្នែកនារី

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណូមពរការងារចាំបាច់

## សំរេច

**ប្រការ ១ :** តែងតាំងគណៈកម្មការកណ្តាលរៀបចំប្រកួតកីឡា **វាយកូនឃ្លីលើតុ** ដណ្តើមពានរង្វាន់ពិភពលោកផ្នែកនារីនៅរាជធានីភ្នំពេញ "ពហុកីឡាដ្ឋានជាតិអូឡាំពិក"នៅថ្ងៃទី២៨-៣០ ខែមករា ឆ្នាំ២០០០ ដែលមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ១-ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ | ប្រធាន |
| ២-ឯកឧត្តម **តូល ឡោះ** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា | អនុប្រធាន |
| ៣-ឯកឧត្តម **មី សាមិឌី** ប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | អនុប្រធាន |
| ៤-ឯកឧត្តម **ជា សុផារ៉ា** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកក្រុងភ្នំពេញ | អនុប្រធាន |
| ៥-អ្នកឧកញ៉ា **ថេង ប៊ុនម៉ា** នាយកក្រុមហ៊ុន ថៃ ប៊ុនរ៉ុង | អនុប្រធាន |
| ៦-ឯកឧត្តម **ឌិត ផនុះ** ប្រធានសហព័ន្ធខ្មែរកីឡា វាយកូនឃ្លីលើតុ | អនុប្រធាន |

៧-តំណាងទីស្តីការគណៈរដ្ឋមន្ត្រី ០១ រូប សមាជិក

៨-តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

៩-តំណាងក្រសួងមហាផ្ទៃ ០១ រូប សមាជិក

១០-តំណាងកងរាជអាវុធហត្ថលើផ្ទៃប្រទេស ០១ រូប សមាជិក

១១-លោក ឡាត់ សំអាត អគ្គនាយករងយុវជន និងកីឡា សមាជិក

១២-លោក មាស សារិន អគ្គនាយករងយុវជន និងកីឡា អគ្គលេខាធិការនៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា សមាជិកទទួលបន្ទុកអចិន្ត្រៃយ៍

១៣-លោក តិន ជាវ៉ អនុប្រធានសហព័ន្ធខ្មែរកីឡាវាយកូនឃ្លីលើតុ សមាជិកទទួលបន្ទុកដឹកជញ្ជូន និងពិធីការ

១៤-លោក ថ្ងំ មុ៊ណ្ណយី អនុប្រធាននាយកដ្ឋាន អប់រំកាយ និងកីឡា លេខាធិការ អចិន្ត្រៃយ៍

១៥-លោក យ៉ែម ឧត្តម អនុប្រធាននាយកដ្ឋាន អប់រំកាយ និងកីឡា សមាជិករៀបចំការប្រកួត

ប្រការ ២ : គណៈកម្មការនេះ មានសិទ្ធិតែងតាំង អនុគណៈកម្មការជំនាញមួយចំនួន ដើម្បីជាជំនួយការក្នុងការអនុវត្តន៍ភារកិច្ច ។

ប្រការ ៣ : គណៈកម្មការនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ គ.ជ.អ.ក និងមានទីស្នាក់ការអចិន្ត្រៃយ៍នៅទីស្នាក់ការ គ.ជ.អ.ក ។

ប្រការ ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអស់លោក ដែលមានឈ្មោះក្នុងប្រការ១ និងស្ថាប័នពាក់ព័ន្ធត្រូវមានភារកិច្ចអនុវត្តអោយបានម៉ឺងម៉ាត់តាមសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

***

រាជធានីភ្នំពេញ, ថ្ងៃទី០៩ ខែ ធ្នូ ឆ្នាំ ១៩៩៩

## សេចក្តីសំរេចលេខ ៨៣ សសរ

### ស្តីពីការកែសំរួលសមាសភាពនៃគណៈបញ្ជាការត្រួតពិនិត្យបំផ្លាញ និង ទប់ស្កាត់ ការចរាចរ ការផលិត ការប្រើប្រាស់ និងការដាំដុះដំណាំគ្រឿងញៀន

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញសេចក្តីសម្រេចលេខ ៩១ សសរ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈបញ្ជាការត្រួតពិនិត្យ បំផ្លាញ និងទប់ស្កាត់ ការចរាចរ ការផលិត ការប្រើប្រាស់ និងការជាំទុះដំណាក់គ្រឿងញៀន
- តាមសំណើរបស់អគ្គលេខាធិការនៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

**សំរេច**

**ប្រការ ១ :** ត្រូវបានកែសម្រួលសមាសភាពនៃគណៈបញ្ជាការត្រួតពិនិត្យ បំផ្លាញ និងទប់ស្កាត់ការចរាចរ ការផលិត ការប្រើប្រាស់ និងការជាំទុះដំណាក់គ្រឿងញៀនគ្រប់ប្រភេទ ដែលមានចែងក្នុងប្រការ ១ នៃសេចក្តីសម្រេចលេខ ៩១ សសរ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតគណៈបញ្ជាការត្រួត ពិនិត្យ បំផ្លាញ និងទប់ស្កាត់ការចរាចរ ការផលិត ការប្រើប្រាស់ និង ការជាំទុះដំណាក់គ្រឿងញៀន ទៅជាដែលមានសមាសភាពថ្មី ដូចខាងក្រោម ៖

១-ឯកឧត្តមឧត្តមសេនីយ៍ឯក **ម៉ុល សារឿន** អគ្គមេបញ្ជាការរង ក.ភ.ខ.ម ប្រធាន

២-ឯកឧត្តមឧត្តមសេនីយ៍ឯក **សូរ ផន** អគ្គនាយករងទី១នគរបាលជាតិ ជាអនុប្រធាន

៣-ឯកឧត្តមឧត្តមសេនីយ៍ទោ **សំរិទ្ធ ឌី** មេបញ្ជាការរងកងទ័ពជើងគោក សមាជិក

៤-ឯកឧត្តមឧត្តមសេនីយ៍ទោ **កែវ សាមួន** មេបញ្ជាការយោធភូមិភាគទី៣ សមាជិក

៥-ឯកឧត្តម **លី ស្វ** អភិបាលខេត្តនិងជាប្រធានគណៈបញ្ជាការឯកភាពខេត្តកំពត សមាជិក

៦-ឯកឧត្តមឧត្តមសេនីយ៍ត្រី **ខៀវ សុគន្ធ** អគ្គលេខាធិការរងនៃ អ.ជ.ប.គ.ញ សមាជិក

៧-ឯកឧត្តមឧត្តមសេនីយ៍ត្រី **ជោង លឹម** ប្រធានមន្ទីរប្រឆាំងគ្រឿងញៀន សមាជិក

**ប្រការ ២ :** ក្រៅពីការកែសម្រួលក្នុងប្រការ ១ ខាងលើនេះ សេចក្តីសម្រេចលេខ ៩១ សសរ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើត គណៈបញ្ជាការត្រួតពិនិត្យ បំផ្លាញ និងទប់ស្កាត់ការចរាចរ ការផលិត ការប្រើប្រាស់ និងការ ជាំទុះដំណាក់គ្រឿងញៀន ស្ថិតនៅជាធរមានដដែល ។

ប្រការ ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួង-ស្ថាប័នពាក់ព័ន្ធ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អគ្គនាយកនគរបាលជាតិ និងអាជ្ញាធរខេត្ត-ក្រុង ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.នាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី
ហត្ថលេខា និងត្រា
ស ខេង

★★★

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ១៩៩៩

# ៣-សារាចរ

## សារាចរលេខ ១០ សរ

## ស្តីពីគោលការណ៍នៃទំនាក់ទំនងជាមួយបរទេស

****

កន្លងមក រាជរដ្ឋាភិបាលបានសង្កេតឃើញថា ក្រសួង និង ស្ថាប័ន មួយចំនួន មិនទាន់អនុវត្តអោយបានត្រឹមត្រូវតាមការកំណត់ នៃសារាចររបស់រាជរដ្ឋាភិបាលលេខ ០៨ សរ ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ១៩៩៥ ស្តីពីទំនាក់ទំនងលើគ្រប់វិស័យ រវាងក្រសួងស្ថាប័ននានានៃព្រះរាជាណាចក្រកម្ពុជាជាមួយបរទេស ដែលជាហេតុធ្វើអោយបាត់របៀបរៀបរយការងារនៃទំនាក់ទំនងអន្តរជាតិ បាត់ប្រសិទ្ធភាពការងារនិងការឯកភាពគ្នា ក្នុងការអនុវត្តនយោបាយក្រៅប្រទេសរបស់រាជរដ្ឋាភិបាល ។

ដើម្បីអោយក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដែលជាសេនាធិការអោយរាជរដ្ឋាភិបាលក្នុងកិច្ចការងារបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាមួយបរទេសលើគ្រប់វិស័យអនុវត្តបានល្អ និង ធានាបានភាពសុខដុមការងារបរទេសទាំងមូល របស់រាជរដ្ឋាភិបាល រាជរដ្ឋាភិបាលសូមណែនាំ ដល់គ្រប់ក្រសួង ស្ថាប័នក្រោមឱវាទរាជរដ្ឋាភិបាល ដូចតទៅ :

**I-តួនាទីនិងភារកិច្ចរបស់ក្រសួងស្ថាប័នក្នុងការចរចានិងចុះហត្ថលេខាលើកិច្ចព្រមព្រៀងអន្តរជាតិ :**

១-កិច្ចព្រមព្រៀង កតិកាសញ្ញា សន្ធិសញ្ញា អនុសញ្ញា ឬ ពិធីសារ ទ្វេភាគី ឬ ពហុភាគី ដែលមានលក្ខណៈនយោបាយទូលំទូលាយ លក្ខណៈសារវ័ន្ត ឬទាក់ទងច្រើនក្រសួង :

**ក-នៅក្នុងប្រទេស :**

-គឺរដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ជាអ្នកចុះហត្ថលេខា ក្រោយពីបានការយល់ព្រមពីរាជរដ្ឋាភិបាល ឬ រដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដោយមានសិទ្ធិប្រទាន ។

-ការចរចាលើកិច្ចព្រមព្រៀងប្រភេទទាំងនេះ ឬ កិច្ចព្រមព្រៀងសហប្រតិបត្តិការទាក់ទង នឹងក្រសួង ក្រសួងត្រូវដឹកនាំនិងចុះហត្ថលេខា ដោយរដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការប្រទានសិទ្ធិ នៃក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដោយមានការចូលរួមពីក្រសួងពាក់ព័ន្ធ ។

**ខ-នៅក្រៅប្រទេស :**

-សមាជិករាជរដ្ឋាភិបាលជាប្រធានគណៈប្រតិភូ ឬ ឯកអគ្គរាជទូតកម្ពុជា អាចចុះហត្ថលេខាបាន ដោយមានសិទ្ធិប្រទាន ដែលចុះហត្ថលេខាដោយប្រមុខរដ្ឋ ប្រមុខរាជរដ្ឋាភិបាល ឬរដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

២-កិច្ចព្រមព្រៀងនានា ដែលមានលក្ខណៈបច្ចេកទេស :

-ស្ថាប័នឬក្រសួងណាមួយ មុននឹងពេភាក្សាចរចាកិច្ចព្រមព្រៀងណាមួយ ត្រូវសុំការឯកភាពជាគោលការណ៍ពីរាជរដ្ឋាភិបាលជាមុនសិន ដោយមានការជូនមតិពីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ។

-ការចរចាលើកិច្ចព្រមព្រៀងបច្ចេកទេស ត្រូវមានមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិចូលរួមជាចាំបាច់ ។ នៅក្រៅប្រទេស ត្រូវមានតំណាងស្ថានទូតកម្ពុជា ចូលរួម ។

-រាល់សមាជិករាជរដ្ឋាភិបាលផ្សេងទៀត អាចចុះហត្ថលេខាបាន លុះត្រាតែមានប្រទានសិទ្ធិពីរាជរដ្ឋាភិបាល ។

-នៅក្នុងប្រទេស ពិធីចុះហត្ថលេខាត្រូវរៀបចំធ្វើឡើង ដោយមានការចូលរួមពីតំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។ នៅក្រៅប្រទេស ត្រូវមានតំណាងស្ថានទូតកម្ពុជាចូលរួម ។

៣-នីតិវិធីក្រោយការចុះហត្ថលេខា :

• កិច្ចព្រមព្រៀងដែលមានលក្ខណៈបច្ចេកទេស ព្រមទាំងឯកសារអម ក៏ដូចជាភស្តុតាងផ្សេងៗ ត្រូវចំលងជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ដើម្បីតាមដានការអនុវត្ត ព្រមទាំងជូនគណៈកម្មការកិច្ចការបរទេសនៃរដ្ឋសភា និង ព្រឹទ្ធសភា ដើម្បីជ្រាបជាព័ត៌មាន ។

• ក្រសួងការបរទេស មានភារកិច្ចបញ្ជូនលិខិតូបករណ៍ នៃការផ្តល់សច្ចាប័ន ( **Instrument of ratification** ) និងលិខិតូបករណ៍ចូលភាគី ( **Instrument of accession** ) ទៅរដ្ឋាភិបាលបរទេស ឬ ស្ថាប័នអន្តរជាតិពាក់ព័ន្ធ ។

**II-ការងារទាក់ទងជាមួយបរទេស :**

-រាល់ការអញ្ជើញគណៈប្រតិភូបរទេស មកធ្វើទស្សនកិច្ចនៅកម្ពុជា ឬ ការចេញទៅធ្វើទស្សនកិច្ចនៅបរទេសរបស់សមាជិករាជរដ្ឋាភិបាលត្រូវសុំការឯកភាពពីរាជរដ្ឋាភិបាល ដោយមានមតិពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីក្រសួងនេះក្តាប់បាននូវនយោបាយការបរទេស រួមរបស់រាជរដ្ឋាភិបាល ព្រមទាំងជួយសំរួលដល់ដំណើរការទស្សនកិច្ចនេះ ។

-គណៈប្រតិភូកម្ពុជា បើគ្មានតំណាងក្រសួងការបរទេសអមដំណើរទេ ត្រូវមានតំណាងស្ថានទូតកម្ពុជាដែលពាក់ព័ន្ធនៅទីនោះ ឬនៅជិតបំផុត ចូលរួមអមដំណើរជាផ្លូវការជានិច្ច ។ ក្នុងករណីទូទៅ ឯកអគ្គរាជ

ទូត មានឋានៈជាមនុស្សទី ២ ក្នុងគណៈប្រតិភូ លើកលែងតែក្នុងករណីពិសេស ដែលមានការណែនាំពីក្នុងប្រទេស ។

-ពេលបញ្ចប់បេសកកម្ម ប្រធានគណៈប្រតិភូ ឬ បេសកជនទាំងនោះ ត្រូវធ្វើរបាយការណ៍ ស្តីពីលទ្ធផលបេសកកម្មភាពរបស់ខ្លួន ជូនរាជរដ្ឋាភិបាល ដោយចំលងជូនក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិដើម្បីតាមដាន ។

-ក្រសួងនិងស្ថាប័ននានា អាចឆ្លើយតាមលិខិតស្នាម ឬប្រាស្រ័យទាក់ទងដោយផ្ទាល់ ជាមួយបរទេស បានសំរាប់ការទាក់ទងនិងអនុវត្តគំរោងការងារបច្ចេកទេស ដោយចំលងនូវរបាយការណ៍ដែលបានសំរេច ឬ អនុវត្តធ្វើជូនក្រសួងការបរទេស ជ្រាបជាពត៌មាន ។

**III**-ការងារពាក់ព័ន្ធ ជាមួយនាយករដ្ឋមន្ត្រី :

ក្នុងការជួបចរចា ឬកិច្ចចុះហត្ថលេខាផ្សេងៗជាមួយបរទេស ដែលមានវត្តមានរបស់នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវសហការគ្នាបំពេញភារកិច្ចនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

ក្នុងស្មារតីបំរើផលប្រយោជន៍ប្រទេសជាតិ អោយមានប្រសិទ្ធភាពនិងឯកភាពរឹងមាំ រាជរដ្ឋាភិបាលតំរូវអោយគ្រប់ក្រសួង ស្ថាប័ននានា និង ខេត្ត ក្រុង នៃព្រះរាជាណាចក្រកម្ពុជា អនុវត្តអោយបានត្រឹមត្រូវ តាមខ្លឹមសារសារាចរនេះ ។

នាយករដ្ឋមន្ត្រី

បត្តសេនា និងព្រា

ហ៊ុន សែន

★★★

# III- ការងារបណ្តាក្រសួង

## ១-ទីស្តីការគណៈរដ្ឋមន្ត្រី

## សេចក្តីសំរេច

រាជធានីភ្នំពេញ,ថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ១៩៩៩

### សេចក្តីសំរេចលេខ ៤៩ សសរ

### ស្តីពីការបង្កើតលេខាធិការដ្ឋាននៃចំណុចការងារ សំរាប់តាមដាន
### របាយការណ៍ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន

*****

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសំរេចលេខ ៧៧ សសរ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ស្តីពីការបង្កើតចំណុចការងារសំរាប់តាមដានរបាយការណ៍ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន
- យោងតាមការងារចាំបាច់

## សំរេច

**ប្រការ ១** : បង្កើតលេខាធិការដ្ឋានមួយរបស់ចំណុចការងារ សំរាប់តាមដានរបាយការណ៍របស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ដែលមានការិយាល័យនៅទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ២** : លេខាធិការដ្ឋាននេះចែកចេញជាពីរក្រុម មានសមាសភាព និងភារកិច្ចដូចខាងក្រោម :

**ក្រុមទី ១** : មានភារកិច្ចធ្វើទំនាក់ទំនងជាមួយបេសកកម្មអង្គការអន្តរជាតិ និងស្វះស្វែងរកជំនួយបច្ចេកទេស និងសំភារៈ សំរាប់បំរើឱ្យសកម្មភាពរបស់ចំណុចការងារមាន ដំណើរការល្អនិងមាន ប្រសិទ្ធភាព ។ ក្រុមទី ១ នេះមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១-ឯកឧត្តម | ស៊ុំ ម៉ានិត | ប្រធាន |
| ២-ឯកឧត្តម | យិន គីមស៊ាន | អនុប្រធាន |
| ៣-លោក | ឡុង សុខា | សមាជិក |
| ៤-កញ្ញា | ជា ចាន់ធឿន | សមាជិក |
| ៥-លោក | ជូ ប៊ុនហៀង | សមាជិក |
| ៦-លោក | ឆេត កល្យាណ | លេខាធិការ |
| ៧-លោក | សំ រិទ្ធី | លេខាធិការ |

**ក្រុមទី ២** : មានភារកិច្ចដូចមានចែងក្នុងប្រការ ៣ នៃសេចក្តីសំរេចលេខ ៧៧ សសរ ចុះថ្ងៃទី២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ លើកលែងតែភារកិច្ចរបស់ក្រុមទី ១ នៃលេខាធិការដ្ឋានរបស់ចំណុច ការងារ ។ ក្រុមទី ២ នេះមានសមាសភាពដូចតទៅ :

| | | |
|---|---|---|
| ១-ឯកឧត្តម | ប៊ុន អ៊ុយ | ប្រធាន |
| ២-ឯកឧត្តម | នឹយ ធឿន | អនុប្រធាន |
| ៣-ឯកឧត្តម | ស៊ុយ ម៉ុងលាង | សមាជិក |

៤-លោក លី ស៊ីវណ្ណា សមាជិក

៥-លោក និត្យ ណាញ សមាជិក

៦-លោក នុ រិទ្ធី សមាជិក

៧-លោក ឃ៉ុន ស៊ីវន សមាជិក

៨-កញ្ញា ហង្ស បូរ៉ានី សមាជិក

៩-លោក សេង រតនៈ សមាជិក

ប្រការ ៣ ៖ ក្រុមទី ១ និងទី ២ ត្រូវធ្វើកិច្ចសហការគ្នាអោយបានជាប់ជាប្រចាំ ដើម្បីឃ្លាំមើល និងធ្វើអធិការកិច្ចលើរោងសហគ្រាសការណ៍ និងសកម្មភាពរបស់អ្នកជំនាញការក្នុងគម្រោង នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន ព្រមទាំងសហគ្រាសការណ៍ និងសកម្មភាពរបស់អង្គការអន្តរជាតិនិងឯកជន ។

ប្រការ ៤ ៖ រាល់ការចំណាយ និងសម្ភារៈបរិក្ខារសំរាប់បំពេញការងារ របស់លេខាធិការដ្ឋាននៃគណៈកម្មការនេះជាបន្ទុករបស់ ទីស្តីការគណៈរដ្ឋមន្ត្រី និងជំនួយឧបត្ថម្ភរបស់សហគមន៍អ្នកផ្តល់ជំនួយ និងអង្គការអន្តរជាតិ ។

ប្រការ ៥ ៖ ប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក ប្រធាននាយកដ្ឋានច្បាប់ និងហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានសរុប ប្រធាននាយកដ្ឋានកសិកម្ម នាយកដ្ឋានពាក់ព័ន្ធចំណុះទីស្តីការគណៈរដ្ឋមន្ត្រីទាំងអស់ និងលោក ដែលមានចែងក្នុងប្រការ ២ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**ស៊ុំ ម៉ានិត**

★★★

## ២-ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### សារាចរ

រាជធានីភ្នំពេញ,ថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ១៩៩៩

### សារាចរណែនាំលេខ ០១៧ សរន.សហវ.ពដ

### ស្តីពីការអនុវត្តន៍ពន្ធលើដីធ្លីមិនបានប្រើប្រាស់

****

យោងតាមបទប្បញ្ញត្តិស្តីពីការពើពន្ធនៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ដែលត្រូវបានប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១ ន.ស ៩៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៤ និងច្បាប់ស្តីពីរបប

ហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ១៩៩៨ ។

អនុវត្តតាមសេចក្តីសម្រេចលេខ ០០៥ សសរ.សហវ.ពស ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៨ ស្តីពីការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងអនុលោមតាមស្មារតីនៃអង្គសិក្ខាសាលាស្តីពីការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ នាថ្ងៃទី២០ និង ២១ ខែ សីហា ឆ្នាំ១៩៩៩ នៅទីរួមខេត្តសៀមរាប ដើម្បីធានាឱ្យការដាក់អនុវត្តពន្ធលើដីធ្លីមិនបានប្រើប្រាស់ ក្នុងក្របខ័ណ្ឌគ្រប់ខេត្ត-ក្រុង ក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមធ្វើការណែនាំដូចតទៅ :

**១-អំពីអត្តសញ្ញាណកម្មនៃដីធ្លីមិនបានប្រើប្រាស់ :**

ដើម្បីឱ្យការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ប្រព្រឹត្តទៅប្រកបដោយយុត្តិធម៌ និងតម្លាភាពនោះចាំបាច់ត្រូវបែងចែកឱ្យបានដាច់ពីគ្នា រវាងដីធ្លីប្រើប្រាស់និងដីធ្លីមិនបានប្រើប្រាស់ ដែលលក្ខណៈវិនិច្ឆ័យទុកសំរាប់យកតម្លៃលើស :

**ក-ដីមានសំណង់ស្ថិតនៅក្នុងតំបន់លំនៅដ្ឋាន :**

ដីប្រភេទនេះច្រើនមាននៅទីក្រុង ទីប្រជុំជន តាមផ្លូវជាតិ តាមដងទន្លេ ឬស្ទឹង ពឹងត្រូវបានចាត់ទុកជាដីប្រើប្រាស់ ដោយមិនត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ប្រសិនបើដីនោះមានសំណង់ ហើយត្រូវបានកម្មសិទ្ធិករដីនោះប្រើប្រាស់ជាកន្លែងស្នាក់នៅជាគោលសំខាន់របស់ខ្លួន និងបានស្នាក់នៅកន្លែងនោះចំនួន ១៨៣ ថ្ងៃ ឬច្រើនជាង គិតចាប់ពីថ្ងៃទី ០១ ខែតុលា នៃឆ្នាំកន្លងទៅ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំ ប្រមូលពន្ធ ។ កន្លែងស្នាក់នៅជាគោលសំខាន់របស់កម្មសិទ្ធិករ គឺជាកន្លែងដែលកម្មសិទ្ធិករបានដេកនៅឬត្រឡប់មកដេកជាទៀង រាល់ថ្ងៃក្រោយពីពេលត្រឡប់ពីបំពេញការងារប្រចាំថ្ងៃ ។ សំរាប់ការកំណត់ក្នុងនេះកម្មសិទ្ធិករម្នាក់ពុំអាចមានទីកន្លែងស្នាក់នៅជាគោលសំខាន់លើសពីមួយកន្លែងបានទេ ។

ដីមានសំណង់ស្ថិតនៅក្នុងតំបន់លំនៅដ្ឋានទាំងឡាយណា ពុំមានលក្ខណៈដូចបានរៀបរាប់ក្នុងចំណុច " ក " ខាងលើ ត្រូវបានចាត់ទុកជាដីធ្លីមិនបានប្រើប្រាស់នឹងត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ។

**ខ-ដីជួលដែលមានសំណង់និងមានការកាន់កាប់ :**

សំដៅលើដីដែលស្ថិតនៅក្នុងតំបន់លំនៅដ្ឋាន ឬស្ថិតនៅក្នុងតំបន់ដែលមានសកម្មភាពសេដ្ឋកិច្ចដូចជា តំបន់ឧស្សាហកម្ម កសិកម្ម ពាណិជ្ជកម្ម ទេសចរណ៍........ហើយដីនោះមានសំណង់ផ្សេងៗដូចជាលំនៅដ្ឋាន អាគារ ឃ្លាំង ..... ដែលបានជួលទាំងដីទាំងសំណង់ទៅឱ្យអតិថិជន ដើម្បីយកឈ្នួលប្រចាំខែ ប្រចាំឆ្នាំ ឬក្រោមកិច្ច សន្យារយៈពេលវែង ។ ដីប្រភេទនេះត្រូវចាត់ទុកជាដីធ្លីប្រើប្រាស់ ដែលមិនជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ លុះណាតែដីទាំងនោះផ្តល់លាភការប្រចាំខែលើសពី៥០% នៃចំនួនមួយភាគដប់ពីរនៃតម្លៃដីនៅក្នុងឆ្នាំប្រមូលពន្ធ គុណនឹងមេគុណ ដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយក្នុងនោះតម្លៃដី ត្រូវកំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ។

ដីផ្សេងៗដែលមានសំណង់មានការកាន់កាប់ ហើយដែលពុំមានលក្ខណៈដូចបានរៀបរាប់ក្នុងចំណុច " ខ " ត្រូវបានចាត់ទុកជាដីធ្លីមិនបានប្រើប្រាស់នឹងត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ។

**គ-ដីដែលមានសកម្មភាពសេដ្ឋកិច្ចស្របតាមការកំណត់តំបន់របស់រដ្ឋ :**

សំដៅលើដីដែលកម្មសិទ្ធិករប្រើប្រាស់សម្រាប់សកម្មភាពសេដ្ឋកិច្ច ដូចជា ដាំដុះ ឧស្សាហកម្ម ពាណិជ្ជកម្ម ទេសចរណ៍ ស្របតាមការកំណត់តំបន់របស់រដ្ឋ.... ។ ដីប្រភេទនេះត្រូវចាត់ទុកជាដីធ្លីប្រើប្រាស់មិនត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ លុះត្រាតែប្រាក់ចំណូលប្រចាំខែបានមកពីសកម្មភាពសេដ្ឋកិច្ចទាំងនោះលើសពីចំនួន ៨០ % នៃចំនួនមួយភាគដប់ពីរនៃតម្លៃដីនៅក្នុងឆ្នាំប្រមូលពន្ធគុណនឹងមេគុណដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយក្នុងនោះតម្លៃដីត្រូវបានកំណត់ដោយគណៈកម្មការវាយតម្លៃមិនបានប្រើប្រាស់ ។ ដីដែលមានសកម្មភាពសេដ្ឋកិច្ចពុំមានលក្ខណៈដូចបានរៀបរាប់ក្នុងចំណុច " គ " ត្រូវបានចាត់ទុកជាដីធ្លីមិនបានប្រើប្រាស់នឹងត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ។

ត្រង់ចំណុច " គ " នេះត្រូវកត់សំគាល់ និងយកចិត្តទុកដាក់លើការខុសគ្នារវាងដីដាំដុះរបស់ប្រជាពលរដ្ឋធ្វើស្រែចំការពិតប្រាកដ ដែលមិនត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងដីរបស់អាជីវករទិញលក់ដីដោយមិនធ្វើអាជីវកម្មលើដីនោះដោយខ្លួនឯង តែប្រគល់ ឬប្រវាស់ឲ្យប្រជាជន ធ្វើអាជីវកម្ម និងករណីដីមួយទៀត ក្រោយពីការជូនដំណឹងស្តីពីការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ អាជីវករទិញលក់ដីខ្លះបានយកដំណាំដូចជា ចេក អំពៅ និងដំណាំហូបផ្លែផ្សេងៗទៀត មកដាំលើដីនោះបំភាន់ភ្នែក ប្រែក្លាយដីមិនបានប្រើប្រាស់ឲ្យមើលឃើញថាជាដីប្រើប្រាស់ក្នុងគោលបំណងគេចវេសមិនព្រមបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ។ ទាក់ទិននឹងដីខាងលើ ដើម្បីកំណត់ឲ្យបានច្បាស់ថាតើដីនោះជាដីប្រើប្រាស់ ឬជាដីមិនបានប្រើប្រាស់ ចាំបាច់ត្រូវគិតគូរកឲ្យឃើញនូវប្រាក់ចំណូលប្រចាំខែ ដែលបានមកពីសកម្មភាពសេដ្ឋកិច្ចដូចបានរៀបរាប់ខាងលើ ។

**ឃ-ដីជាកម្មសិទ្ធិរបស់រដ្ឋជួលឲ្យនិតិបុគ្គលឬរូបវន្តបុគ្គល :**

ដីប្រភេទនេះជាដីសាធារណៈ ដែលជាកម្មសិទ្ធិរបស់រដ្ឋ ទោះបីមាននៅក្នុងបញ្ជីសារពើភ័ណ្ឌ ឬនៅក្រៅបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋក្តី ។ បើដីរបស់រដ្ឋនេះត្រូវបានជួលទៅឲ្យនិតិបុគ្គល ឬ រូបវន្តបុគ្គលណាមួយ ហើយប្រាក់ឈ្នួលប្រចាំខែបានមកតិចជាង ៨០% នៃចំនួនមួយភាគដប់ពីរ នៃតម្លៃដីនៅក្នុងឆ្នាំប្រមូលពន្ធគុណនឹងមេគុណ ដែលកំណត់ដោយប្រកាសរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយក្នុងនោះតម្លៃដីត្រូវបានកំណត់ ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់នោះ ដីប្រភេទនេះត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ។

**ង-ដីដែលស្ថិតនៅក្រោមកិច្ចព្រមព្រៀងវិនិយោគ :**

ដីប្រភេទនេះ រួមមានដីស្ថិតនៅក្រោមកិច្ចព្រមព្រៀងវិនិយោគនិងដីសម្បទាន ដែលបានការ អនុញ្ញាតដោយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ( CDC ) ឲ្យធ្វើវិនិយោគលើវិស័យអ្វីមួយ ឬដីសម្បទានរយៈពេលខ្លី មធ្យម ឬវែង ដែលបានទទួលការអនុញ្ញាពីរាជរដ្ឋាភិបាលឲ្យអនុវត្តនូវគំរោងអ្វីមួយ ។ ប្រសិនបើដីវិនិយោគ ឬ ដីសម្បទាននោះពុំបាន ឬពុំទាន់ដំណើរការដោយមូលហេតុប្រធានសក្តិរងគ្រោះ ដោយទឹកជំនាន់ជាប្រចាំ ដីចំការ

មីន ឬមូលហេតុអសន្តិសុខផ្សេងៗនោះ ពុំត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ទេ ប៉ុន្តែរយៈពេលនៃការអាក់អាន ឬការពន្យាពេលនោះ មានការបញ្ជាក់ទទួលយល់ព្រម ពីស្ថាប័នជំនាញមានសមត្ថកិច្ចនិងពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**២-បុគ្គលដែលត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ :**

បុគ្គលដែលត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ គឺជាកម្មសិទ្ធិករនៃដីធ្លីមិនបានប្រើប្រាស់ ។ ការបង់ពន្ធនេះមិនមែនជាលក្ខខណ្ឌបញ្ជាក់កម្មសិទ្ធិស្របច្បាប់លើដីធ្លីទេ ។ ក្នុងការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ ពាក្យ " កម្មសិទ្ធិករ " សំដៅដល់នីតិបុគ្គល ឬរូបវន្តបុគ្គលណា ដែលកំពុងកាន់កាប់ ឬអាជ្ញាធរដែនដីចាប់ពីថ្នាក់ ឃុំ សង្កាត់ ឡើងទៅបានចេញឯកសារផ្លូវការទទួលស្គាល់សិទ្ធិរបស់បុគ្គលនោះ ក្នុងការប្រើប្រាស់ដីក្នុងតំបន់ណាមួយជាលក្ខណៈជាប់លាប់ក្តី ឬបណ្តោះអាសន្នក្តី ។

កម្មសិទ្ធិករម្នាក់ជារូបវន្តបុគ្គលគឺជាគ្រួសារមួយ " ឪពុក ម្តាយ សាមីខ្លួន ប្រពន្ធ កូន នៅក្នុង បន្ទុក " ឬមេគ្រួសារ និងសមាជិកក្នុងបន្ទុកមានឈ្មោះក្នុងប័ណ្ណគ្រួសារ ដែលចេញដោយស្ថាប័នមានសមត្ថកិច្ច ។

**៣-មូលដ្ឋានកំណត់ពន្ធ និង អត្រាពន្ធ :**

មូលដ្ឋានកំណត់ពន្ធគឺជាផ្ទៃដីគិតតាមថ្លៃទីផ្សារ តាមទីក្រុងនិងតាមតំបន់នីមួយៗ ដែលវាយតម្លៃទៅតាមតម្លៃគិតក្នុងមួយម៉ែត្រក្រឡា កំណត់ដោយគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ យ៉ាងយឺតបំផុតនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំប្រមូលពន្ធ ។

ក្នុងការគិតពន្ធ ត្រូវបានអនុញ្ញាតឲ្យកាត់ចេញពីមូលដ្ឋានកំណត់ពន្ធ ចំនួន ១.២០០ ម៉ែត្រក្រឡា ក្នុងដីមួយកន្លែង ។

ពន្ធនេះត្រូវកំណត់តាមអត្រា២% លើមូលដ្ឋានកំណត់ពន្ធនិងត្រូវបានគណនាដូចតទៅ :

ប្រាក់ពន្ធត្រូវបង់ = ( ផ្ទៃដីសរុប- ១.២០០$ម^២$ ) × មូលដ្ឋានកំណត់ × ២ %

**៤-អំពីការប្រកាសបង់ពន្ធ :**

ពន្ធលើដីធ្លីមិនបានប្រើប្រាស់គឺជាប្រភេទពន្ធអនុវត្តតាមវិធីឆ្លើយប្រកាស ។ កម្មសិទ្ធិករនៃដីជាប់ពន្ធមានកាតព្វកិច្ចដាក់លិខិតប្រកាសបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ ដោយគណនាប្រាក់ពន្ធខ្លួនឯងទៅតាមគំរូលិខិតប្រកាស ដែលនាយកដ្ឋានពន្ធដារបានផ្តល់ជូន ហើយត្រូវបង់ពន្ធឲ្យបានចប់សព្វគ្រប់យ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំសារពើពន្ធនីមួយៗជូនទៅផ្នែកពន្ធដារ នៅកន្លែងដែលដីធ្លីស្ថិតនៅ ។ ដីមួយកន្លែងត្រូវធ្វើលិខិតឆ្លើយប្រកាស ២ច្បាប់ ។

**៥-នីតិវិធីនៃការកំណត់ពន្ធ និង វិធានការតឹងទារបំណុលពន្ធ :**

ចាប់ពីថ្ងៃទី ១ តុលា នៃឆ្នាំប្រមូលពន្ធ ផ្នែកពន្ធដារមានសិទ្ធិត្រួតពិនិត្យលើមូលដ្ឋានកំណត់ពន្ធ និងការបង់ពន្ធរបស់កម្មសិទ្ធករម្នាក់ៗ ។ បើពិនិត្យទៅឃើញថាកម្មសិទ្ធិករណាម្នាក់មាន :

-ការមិនបានបំពេញកាតព្វកិច្ចដាក់លិខិតប្រកាសបង់ពន្ធ

-ការបង់ពន្ធខ្វះដោយប្រកាសមិនអស់ដីដែលខ្លួនមាន

-ការបង់ពន្ធកើតឡើងមិនតាមការកំណត់

ពេលនោះផ្នែកពន្ធដារត្រូវធ្វើ :

**ក-លិខិតរំលឹកប្រកាសបង់ពន្ធ** ( គំរូទី ១ )

លិខិតរំលឹកប្រកាសបង់ពន្ធ ត្រូវធ្វើដោយផ្នែកពន្ធដារផ្ញើជូនទៅកម្មសិទ្ធិករ ដែលមិនបានដាក់លិខិតប្រកាសបង់ពន្ធ ដោយមុនរយៈពេល ១៥ ថ្ងៃសំរាប់ការដាក់លិខិតប្រកាសបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់នេះ ។

**ខ-ការជូនដំណឹងស្តីពីការកំណត់ពន្ធជាឯកតោភាគី** ( គំរូទី២ )

ក្នុងករណីកម្មសិទ្ធិករមិនបានមកបំពេញកាតព្វកិច្ច ប្រកាសបង់ពន្ធតាមការកំណត់ ដូចបានជំរាបជូនក្នុងលិខិតរំលឹកប្រកាសបង់ពន្ធ តាមការតម្រូវនៃបទប្បញ្ញត្តិស្តីពីវិធាន និងនីតិវិធីសារពើពន្ធ ផ្អែកតាមមាត្រា ១១៦ នៃច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧ ផ្នែកពន្ធដារចាំបាច់ត្រូវធ្វើការកំណត់ពន្ធជាឯកតោភាគី ។ ក្នុងករណីនេះប្រាក់ពន្ធត្រូវបានកំណត់នឹងត្រូវបង់ ក្នុងរយៈពេល៣ថ្ងៃក្រោយកាលបរិច្ឆេទប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធ ។

**គ-ការជូនដំណឹងស្តីពីការកំណត់ពន្ធឡើងវិញ** ( គំរូទី៣ )

ការកំណត់ពន្ធឡើងវិញត្រូវអនុវត្តចំពោះ កម្មសិទ្ធិករដែលបានដាក់លិខិតប្រកាស ប៉ុន្តែមានលក្ខណៈមិនគ្រប់គ្រាន់មិនត្រឹមត្រូវ ឬមានការភ្លាំងភ្លាត់ ដែលនាំឲ្យប្រាក់ពន្ធបានបង់មានចំនួនតិចជាងប្រាក់ពន្ធ ដែលបានកំណត់ដោយបទប្បញ្ញត្តិស្តីពីសារពើពន្ធ ។

កម្មសិទ្ធិករមានរយៈពេល៣០ថ្ងៃ ដើម្បីឆ្លើយតបចំពោះការកំណត់ពន្ធឡើងវិញ ទៅផ្នែកពន្ធដារដែលទទួលបន្ទុកធ្វើការកំណត់ពន្ធឡើងវិញនេះ ។ ក្នុងរយៈពេលនេះកម្មសិទ្ធិករអាចទទួលយក ឬជំទាស់ចំពោះការកំណត់ពន្ធឡើងវិញ ។ បើសិនជាពុំបានឆ្លើយតបកម្មសិទ្ធិករត្រូវចាត់ទុកថា យល់ព្រមចំពោះការកំណត់ពន្ធឡើងវិញនេះ ។

**ឃ-លិខិតជូនដំណឹងទារបំណុលពន្ធសំរាប់ការកំណត់ពន្ធជាឯកតោភាគី** ( គំរូទី៤-ក )

ក្រោយពីមានការកំណត់ពន្ធជាឯកតោភាគី ផ្នែកកំណត់ពន្ធត្រូវបញ្ចូនលទ្ធផល ដោយធ្វើជាតារាងឥណទេយ្យសារពើពន្ធ និងលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធជាឯកតោភាគី ទៅឲ្យផ្នែកប្រមូលពន្ធ ។ ក្រោយពីបានទទួលលិខិតទាំងនេះ ផ្នែកប្រមូលពន្ធត្រូវធ្វើលិខិតជូនដំណឹងទារបំណុលពន្ធ ហើយត្រូវផ្ញើលិខិតជូនដំណឹងស្តីពីការកំណត់ពន្ធជាឯកតោភាគី និងលិខិតជូនដំណឹងទារបំណុលពន្ធទៅឲ្យកម្មសិទ្ធិករ ។

-លិខិតជូនដំណឹងទារបំណុលពន្ធត្រូវមានចុះបញ្ជាក់យ៉ាងច្បាស់ថា បំណុលពន្ធនិងទោសទណ្ឌជាប់ទាក់ទិនត្រូវបានកំណត់នឹងត្រូវបង់ នៅក្នុងរយៈពេល៣ថ្ងៃក្រោយកាលបរិច្ឆេទប្រគល់ទទួលលិខិតនេះ ។

**ង-លិខិតជូនដំណឹងទារបំណុលពន្ធសំរាប់ការកំណត់ពន្ធឡើងវិញ** ( គំរូទី៤-ខ )

ក្រោយពីបានទទួលតារាងឥណទេយ្យសារពើពន្ធពីផ្នែកកំណត់ពន្ធរួចហើយ ផ្នែកប្រមូលពន្ធត្រូវធ្វើលិខិតជូនដំណឹងទារបំណុលពន្ធ ផ្ញើទៅឲ្យកម្មសិទ្ធិករនៃដីធ្លីមិនបានប្រើប្រាស់ ។

-លិខិតជូនដំណឹងទារបំណុលពន្ធ ត្រូវមានចុះបញ្ជាក់យ៉ាងច្បាស់ថា បំណុលពន្ធនិងទោសទណ្ឌជាប់ទាក់ទិនត្រូវកំណត់នឹងត្រូវបង់រយៈពេល៣០ថ្ងៃ ក្រោយកាលបរិច្ឆេទប្រគល់ទទួលលិខិតនេះ ។

**ច-លិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ** ( ល/រូទី ៥ )

-ក្នុងករណីដែលកម្មសិទ្ធិករមិនបានបង់បំណុលពន្ធ ក្នុងរយៈពេល៣០ថ្ងៃក្រោយកាលបរិច្ឆេទប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធ ឬ ក្នុងរយៈពេល៣ថ្ងៃក្រោយកាលបរិច្ឆេទប្រគល់លិខិតជូនដំណឹងទារបំណុលពន្ធសំរាប់ការកំណត់ពន្ធជាឯកតោភាគី ផ្នែកប្រមូលពន្ធត្រូវចេញលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ ។

ក្នុងរយៈពេល១៥ថ្ងៃក្រោយពីថ្ងៃបានទទួលលិខិតរំលឹកការទារបំណុលពន្ធ កម្មសិទ្ធិករនៅមិនព្រមមកទូទាត់បំណុលពន្ធទៀតនោះ ផ្នែកពន្ធដារត្រូវអនុវត្តនូវវិធានការតឹងទារបំណុលពន្ធ ដែលរួមមាន :

-ការឃាត់ទុកគណនីនៅធនាគាររបស់អ្នកជំពាក់បំណុលពន្ធ

-ការបញ្ឈប់ប្រតិបត្តិការនាំចេញ នាំចូល

-ការរឹបអូស ការលក់ទ្រព្យសម្បត្តិរបស់អ្នកជំពាក់បំណុលពន្ធ

-ការទុកជាមោឃៈនូវលិខិតអនុញ្ញាតនិងអាជ្ញាប័ណ្ណ

គណៈកម្មការតឹងទារបំណុលសារពើពន្ធតាមបណ្ដាខេត្ត ក្រុង នីមួយៗ មានភារកិច្ចអនុវត្តនូវការងារខាងលើនេះ ។

**៦-អំពីទោសទណ្ឌ :**

ការបង់ពន្ធខ្វះ ការបង់ពន្ធយឺត ឬការមិនបានដាក់លិខិតប្រកាសសារពើពន្ធ ត្រូវរងការដាក់ទោសអនុវត្តនូវមាត្រា១១៦ និងមាត្រា១១៧ នៃច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧ ។ ទន្ទឹមនឹងនោះផ្អែកតាមមាត្រា ១៣១ និងមាត្រា ១៣២ នៃច្បាប់ដដែលខាងលើ កម្មសិទ្ធិករត្រូវបង់ប្រាក់ពន្ធបន្ថែមស្មើនឹង ១០% ២៥% ឬ៥០% នៃចំនួនប្រាក់ពន្ធ ដែលបង់ខ្វះបូកបន្ថែមការប្រាក់២% នៃចំនួនប្រាក់ពន្ធដែលបង់ខ្វះសំរាប់ខែនីមួយៗ ឬចំណែកនៃខែដែលប្រាក់ពន្ធខ្វះមិនទាន់បានបង់ ។

**៧-អំពីការលើកទឹកចិត្តលើការប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់ :**

ការលើកទឹកចិត្តចំពោះការប្រមូលពន្ធជាក់ស្តែង និង មានប្រសិទ្ធិភាពត្រូវបានកំណត់ដោយច្បាប់ស្តីពីសារពើពន្ធប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ត្រង់មាត្រា៩៧ ដែលបានចែងថា “ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវកសាងប្រព័ន្ធលើកទឹកចិត្តមួយសំរាប់មន្ត្រីភ្នាក់ងាររដ្ឋបាលសារពើពន្ធ ” ចំពោះមុខដើម្បីឲ្យការគ្រប់គ្រងប្រមូលពន្ធលើដីធ្លីមិនបានប្រើប្រាស់នាំមកនូវប្រសិទ្ធិភាពខ្ពស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អនុញ្ញាតឲ្យបង្កើតបេឡារង្វាន់មួយ ដែលគ្រប់គ្រងនិងបែងចែកដោយសាខាពន្ធដារខេត្ត-ក្រុង ។ ប្រភពចំណូលសំរាប់បង្កើតបេឡារង្វាន់នេះ គឺបានមកពីចំណូលអំពីពន្ធលើដីធ្លីមិនបានប្រើប្រាស់ ។ បុគ្គលដែលត្រូវទទួលប្រាក់រង្វាន់ គឺមន្ត្រីភ្នាក់ងាររដ្ឋបាលសារពើពន្ធអាជ្ញាធរឃុំ អាជ្ញាធរស្រុក គណៈកម្មការ និងអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់ ។

អត្រានៃប្រាក់រង្វាន់ត្រូវបានកំណត់ស្មើនឹង ១០% ( ដប់ភាគរយ ) នៃចំណូលបានមកពីពន្ធលើដីធ្លីមិនបានប្រើប្រាស់ និងត្រូវបានអនុញ្ញាតឲ្យដកមុនពេលបង់ចូលទៅរតនាគារខេត្ត-ក្រុង និងកាត់បញ្ចូលក្នុងបេឡាមួយ ដែលបានបង្កើតឡើងសំរាប់ចែកជូនរង្វាន់លើកទឹកចិត្តនេះ ។

សមាមាត្រនៃការបែងចែកប្រាក់រង្វាន់ត្រូវបានកំណត់ដូចតទៅ :

១- ១០% ( ដប់ភាគរយ ) បែងចែកជូនគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

២- ១៥% ( ដប់ប្រាំភាគរយ ) បែងចែកជូននាយកដ្ឋានពន្ធដារ

៣- ២០% ( ម្ភៃភាគរយ ) បែងចែកជូនសាខាពន្ធដារខេត្ត-ក្រុង

៤- ២៥% ( ម្ភៃប្រាំភាគរយ ) បែងចែកជូនអនុគណៈកម្មការវាយតម្លៃដីមិនបានប្រើប្រាស់

៥- ១៥% ( ដប់ប្រាំភាគរយ ) បែងចែកជូនអាជ្ញាធរស្រុក

៦- ១៥% ( ដប់ប្រាំភាគរយ ) បែងចែកជូនអាជ្ញាធរឃុំ

ការបែងចែកប្រាក់រង្វាន់នេះអនុវត្តចំពោះតែខេត្ត-ក្រុង ស្រុក-ឃុំណា ដែលបានចំណូលមកអំពីពន្ធលើដីធ្លីមិនបានប្រើប្រាស់ ។ ប្រាក់រង្វាន់ដែលទទួលបានក្នុងខែនីមួយៗ សាខាពន្ធដារត្រូវបែងចែកតាមសមាមាត្រដូចបានកំណត់ខាងលើ និងត្រូវធ្វើរបាយការណ៍មកនាយកដ្ឋានពន្ធដាររៀងរាល់ដំណាច់ខែ ។

បេឡាប្រាក់រង្វាន់ ត្រូវគ្រប់គ្រងដោយអនុវត្តកិច្ចបញ្ជីកាឲ្យបានត្រឹមត្រូវ តាមសេចក្តីណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

សេចក្តីណែនាំនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

រដ្ឋលេខាធិការ

ហត្ថលេខា និងត្រា

**គង់ វិបុល**

★★★

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

****

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ                                                                                    គំរូទី១

នាយកដ្ឋានពន្ធដារ

សាខាពន្ធដារខេត្ត-ក្រុង............

លេខ:..........................ពដ                                    ....................ថ្ងៃទី .........ខែ.........ឆ្នាំ.........

**លិខិតរំលឹក**

**ប្រកាសបង់ពន្ធលើដីធ្លីមិនបានប្រើប្រាស់**

**ជំរាបមក**

លោក-លោកស្រី.......................................................................................

អាសយដ្ឋាន.............................................................................................

តាមការពិនិត្យស្ថានភាពសារពើពន្ធរបស់លោក-លោកស្រីឃើញថា : លោក-លោកស្រីនៅពុំទាន់បានផ្តល់មកសាខាពន្ធដារខេត្ត-ក្រុងនូវលិខិតប្រកាសសារពើពន្ធ ដូចខាងក្រោម :

-ពន្ធលើដីធ្លីមិនបានប្រើប្រាស់សំរាប់ឆ្នាំ............................

-ទីតាំងស្ថិតនៅ : ក្នុងតំបន់លេខ...............ភូមិ........................ឃុំ-សង្កាត់................ស្រុក-ខ័ណ្ឌ..........................ខេត្ត-ក្រុង..........................ដែលមានប្លង់កាន់កាប់លេខ................ចុះថ្ងៃទី................ខែ....................ឆ្នាំ...................... ។

ដោយលោក-លោកស្រីបានល្មើសនឹងបទប្បញ្ញត្តិ នៃច្បាប់ស្តីពីសារពើពន្ធរបស់ព្រះរាជាណាចក្រកម្ពុជា និងជាពិសេសល្មើសនឹងមាត្រា ៣២ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ និងមាត្រា ១០៤ នៃច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧ ។ យើងទុករយៈពេល ១៥ ថ្ងៃ គិតពីថ្ងៃលោក-លោកស្រីបានទទួលលិខិតនេះសំរាប់លោក-លោកស្រីអញ្ជើញមកបំពេញកាតព្វកិច្ចសារពើពន្ធឲ្យបានត្រឹមត្រូវតាមច្បាប់កំណត់ ។ បើហួសរយៈពេលកំណត់នេះ លោក-លោកស្រី នឹងត្រូវរងការកំណត់ពន្ធជាឯកតោភាគីពីអង្គភាពពន្ធដារទៅតាមការកំណត់ក្នុងមាត្រា ១១៦ នៃច្បាប់ស្តីពីការសារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ។

ម្យ៉ាងទៀតលោក-លោកស្រីត្រូវរងការពិន័យជាប្រាក់ដូចបានចែងក្នុងមាត្រា ១៣១-១៣២-១៣៣ នៃច្បាប់ស្តីពីសារពើពន្ធ ។ ក្នុងករណីប្រើល្បិចកលពន្យាពេលសំដៅគេចវេសពីការបង់ពន្ធនោះ លោក-លោកស្រីអាចនឹងត្រូវជាកម្មវត្ថុនៃបណ្តឹងព្រហ្មទ័ណ្ឌ ។

សូមលោក-លោកស្រី ទទួលនូវមនោសញ្ចេតនារាប់អានដ៏ជ្រាលជ្រៅ អំពីខ្ញុំ ។

ប្រធានសាខាពន្ធដារខេត្ត-ក្រុង

★★★

# ដកស្រង់ចេញពីច្បាប់

## ស្តីពី

## ហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥

****

### III-ពន្ធលើដីធ្លីមិនបានប្រើប្រាស់

មាត្រា ២៦ ........................................................................................................

មាត្រា ២៧ ........................................................................................................

មាត្រា ២៨ ........................................................................................................

មាត្រា ២៩ ........................................................................................................

មាត្រា ៣០ ........................................................................................................

មាត្រា ៣១ ........................................................................................................

មាត្រា ៣២ :

កម្មសិទ្ធិករ នៃដីធ្លីជាប់ពន្ធមានភារកិច្ចត្រូវគណនាប្រាក់ពន្ធតាមតំរូវលិខិតប្រកាសផ្តល់ដោយអង្គភាពពន្ធ និងត្រូវបង់ពន្ធនេះយ៉ាងយឺតបំផុតនៅថ្ងៃទី៣០ ខែកញ្ញា នៃឆ្នាំនិមួយៗ ជូនទៅផ្នែកពន្ធនៅកន្លែងដែលដីធ្លីជាប់ពន្ធស្ថិតនៅ ។ ដីធ្លីជាប់ពន្ធនិមួយៗ ត្រូវធ្វើលិខិតប្រកាស ១ ច្បាប់ ។

មាត្រា ៣៣ ........................................................................................................

មាត្រា ៣៤ ........................................................................................................

មាត្រា ៣៥ ........................................................................................................

មាត្រា ៣៦ ........................................................................................................

★★★

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

****

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ　　　　　　　　　　　　　　　　　　　　គំរូទី២

នាយកដ្ឋានពន្ធដារ

សាខាពន្ធដារខេត្ត-ក្រុង..................

លេខ...........................ពដ　　　　　　　　....................ថ្ងៃទី ..........ខែ..........ឆ្នាំ..........

## លិខិតជូនដំណឹង

## ស្ដីពី

## ការកំណត់ពន្ធជាឯកតោភាគី

**ជំរាបមក**

លោក-លោកស្រី..........................................................................................

អាសយដ្ឋាន..............................................................................................

តាមការពិនិត្យស្ថានភាពសារពើពន្ធរបស់លោក-លោកស្រី ស្ដីពីពន្ធលើដីធ្លីមិនបានប្រើប្រាស់ក្នុងឆ្នាំ ...............

ដោយហេតុថា លោក-លោកស្រីមិនបានមកបំពេញកាតព្វកិច្ចសារពើពន្ធតាមកាលកំណត់ក្នុងច្បាប់ និងដោយអនុវត្តតាមមាត្រា ១១៦ នៃច្បាប់ស្ដីពីសារពើពន្ធឆ្នាំ១៩៩៧ ផ្នែកពន្ធដារសំរេចកំណត់ពន្ធជាឯកតោភាគី ដូចមានមូលដ្ឋានគិតពន្ធ និង ចំនួនប្រាក់ពន្ធដែលត្រូវបង់ ដូចបានគណនាជូននៅខាងខ្នងលិខិតនេះ ។

សូមបញ្ជាក់ថា អនុវត្តតាមមាត្រា ១៣១-១៣២ នៃច្បាប់ស្ដីពីសារពើពន្ធដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ គឺក្រៅពីប្រាក់ពន្ធដែលត្រូវបង់ ត្រូវបូកពន្ធបន្ថែម ៤០ % និង ការប្រាក់លើតកាំង ២ % ក្នុងមួយខែ នៃចំនួនប្រាក់ពន្ធដែលបានកំណត់ថែមទៀត ។

សូមលោក-លោកស្រី ទទួលនូវសេចក្ដីគោរពរាប់អានដ៏ជ្រាលជ្រៅ អំពីខ្ញុំ ។

ប្រធានសាខាពន្ធដារខេត្ត-ក្រុង

★★★

**I-ការគណនា :**

១-មូលដ្ឋានកំណត់ពន្ធ :

ក្នុងការិយបរិច្ឆេទឆ្នាំ ................លោក-លោកស្រីមានដីធ្លីពុំបានប្រើប្រាស់មួយកន្លែងស្ថិតក្នុងតំបន់លេខ...................ឃុំ-សង្កាត់..............................ស្រុក-ខណ្ឌ..............................ខេត្ត-ក្រុង.........................ដែលមានប្លង់កាន់កាប់លេខ.......................ចុះថ្ងៃទី.....................ខែ...............ឆ្នាំ................... ។

ដូចនេះ លោក-លោកស្រីត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ :

-ទំហំដីសរុប = ..............................

-ទំហំដីត្រូវលើកលែង = ១.២០០ ម$^2$

-ទំហំដីត្រូវជាប់ពន្ធ = ..............................

-តម្លៃដីក្នុង ០១ ម$^2$ = ..............................

ដូចនេះ

.............................. X ......................= ..........................

២-ការកំណត់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ :

ផ្អែកតាមមាត្រា ៣១ នៃច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ។ ពន្ធនេះត្រូវកំណត់តាមអត្រា ២% លើមូលដ្ឋានកំណត់ពន្ធដែលបានគិតខាងលើ ។

ដូចនេះ :

......................... X ២ % = ................................

**II-ទោសទណ្ឌ :**

លោក-លោកស្រីពុំបានដាក់លិខិតប្រកាសបង់ពន្ធប្រចាំឆ្នាំ ............. ។ ផ្អែកតាមមាត្រា ១៣១-១៣២ នៃច្បាប់ស្តីពីសារពើពន្ធឆ្នាំ ១៩៩៧ លោក-លោកស្រីត្រូវបង់ប្រាក់ពន្ធបន្ថែមចំនួន ៤០ % និងការប្រាក់យឺតយ៉ាវចំនួន ២ % ក្នុង ១ខែ ។

**១-ប្រាក់ពន្ធបន្ថែម :**

.................................... X ៤០ % = ..............................

**២-ការប្រាក់យឺតយ៉ាវ :**

- ប្រាក់ពន្ធត្រូវបង់ = ..............................
- ថ្ងៃចាប់ផ្តើមគិតការប្រាក់ = ..............................
- ថ្ងៃចុងក្រោយ = ..............................
- ចំនួនខែ = ..............................

ដូចនេះ

........................... x ២ % x ............ ខែ = ...........................

**III-សរុបប្រាក់ពន្ធត្រូវបង់ :**

- ពន្ធលើដីធ្លីមិនបានប្រើប្រាស់ = ...........................
- ប្រាក់ពន្ធបន្ថែម = ...........................
-ការប្រាក់យឺតយ៉ាវ = ...........................

សរុប = ...........................

ជាអក្សរ " ................................................................................ " ។

★★★

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

****

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គំរូទី៣

នាយកដ្ឋានពន្ធដារ

សាខាពន្ធដារខេត្ត-ក្រុង.............

លេខ...........................ពដ ......................ថ្ងៃទី ..........ខែ..........ឆ្នាំ..........

## លិខិតជូនដំណឹង

ស្ដីពី

**ការកំណត់ពន្ធឡើងវិញ**

**ជំរាបមក**

លោក-លោកស្រី....................................................................................

អាស័យដ្ឋាន........................................................................................

តាមការពិនិត្យលើលិខិតប្រកាស និង ពិនិត្យជាក់ស្ដែងពីពន្ធលើដីធ្លីមិនបានប្រើប្រាស់ក្នុងឆ្នាំ....... របស់លោក-លោកស្រី ផ្នែកពន្ធដារត្រូវកែប្រែទិន្នន័យសំរាប់ជាមូលដ្ឋានគណនាប្រាក់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ និង តម្រូវឲ្យលោក-លោកស្រីបង់ប្រាក់ពន្ធដារបន្ថែម អាស្រ័យដោយមូលហេតុដូចបានបញ្ជាក់ជូនខាងខ្នងលិខិតនេះ ។

លោក-លោកស្រីមានរយៈពេលចំនួន ៣០ថ្ងៃ ដើម្បីឆ្លើយតបមកយើងខ្ញុំវិញអំពីការយល់ព្រម ឬ យោបល់របស់លោក-លោកស្រី ការមិនបានឆ្លើយតបក្នុងរយៈពេលនេះចាត់ទុកថា លោក-លោកស្រីបានយល់ព្រមតាមការកំណត់របស់ផ្នែកពន្ធដារ ។

សូមបញ្ជាក់ថា អនុវត្តតាមមាត្រា ១៣១ ១៣២ នៃច្បាប់ស្ដីពីសារពើពន្ធឆ្នាំ១៩៩៧ គឺប្រាក់ពន្ធបានមកពីការកំណត់នេះ ត្រូវបូកពន្ធបន្ថែម ១០ % ឬ ២៥ % និង ការប្រាក់យឺតយ៉ាវ ២ % ក្នុងមួយខែ នៃចំនួនប្រាក់ពន្ធដែលបានកំណត់ ។

សូមលោក-លោកស្រី ទទួលនូវសេចក្ដីរាប់អានដ៏ស្មោះស្ម័គ្រ អំពីខ្ញុំ ។

ប្រធានសាខាពន្ធដារខេត្ត-ក្រុង

★★★

**I-ការគណនា :**

**១-មូលដ្ឋានកំណត់ពន្ធឡើងវិញ :**

ក្នុងការិយបរិច្ឆេទឆ្នាំ ...............លោក-លោកស្រីមានដីធ្លីពុំបានប្រើប្រាស់មួយកន្លែងស្ថិតក្នុងតំបន់លេខ..................ឃុំ-សង្កាត់..........................ស្រុក-ខណ្ឌ............................ ខេត្ត-ក្រុង........................ដែលមានប្លង់កាន់កាប់លេខ.....................ចុះថ្ងៃទី.................. ខែ..............ឆ្នាំ.................. ។

ដូចនេះ លោក-លោកស្រីត្រូវជាប់ពន្ធលើដីធ្លីមិនបានប្រើប្រាស់ :

-ទំហំដីសរុប = ............................

-ទំហំដីត្រូវលើកលែង = ១.២០០ ម$^{២}$

-ទំហំដីត្រូវជាប់ពន្ធ = ............................

-តម្លៃដីក្នុង ០១ ម$^{២}$ = ............................

ដូចនេះ

................................ X ..........................= ..........................

**២-ការកំណត់ពន្ធឡើងវិញ :**

ផ្អែកតាមមាត្រា ៣១ នៃច្បាប់ស្ដីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៥ ។ ពន្ធនេះត្រូវកំណត់តាមអត្រា ២% លើមូលដ្ឋានកំណត់ពន្ធដែលបានគិតខាងលើ ។

ដូចនេះ :

......................... **X ២ %** = ...............................

**-ប្រាក់ពន្ធត្រូវបង់** = ...............................

**-ប្រាក់ពន្ធបានបង់** = ...............................

-ប្រាក់ពន្ធត្រូវបង់បន្ថែម = ...............................

**II-ទោសទណ្ឌ :**

លោក-លោកស្រីបានប្រកាសបង់ពន្ធ...................... ផ្ទុយតាមមាត្រា ១៣២ នៃច្បាប់ស្តីពីសារពើពន្ធឆ្នាំ ១៩៩៧ លោក-លោកស្រីត្រូវបង់ប្រាក់ពន្ធបន្ថែមចំនួន ១០% ឬ២៥ % និងការប្រាក់យឺតយ៉ាវចំនួន ២ % ក្នុង ១ខែ ។

**១-ប្រាក់ពន្ធបន្ថែម :**

.................................... X ១០ % ឬ ២៥ % = ............................

**២-ការប្រាក់យឺតយ៉ាវ :**

- ប្រាក់ពន្ធត្រូវបង់បន្ថែម = .............................
- ថ្ងៃចាប់ផ្តើមគិតការប្រាក់ = .............................
- ថ្ងៃចុងក្រោយ = .............................
- ចំនួនខែ = .............................

**ដូចនេះ**

........................... X ២ % X ............ ខែ = ..........................

**III-សរុបប្រាក់ពន្ធត្រូវបង់ :**

- ពន្ធលើដីធ្លីមិនបានប្រើប្រាស់ = ..........................
- ការប្រាក់យឺតយ៉ាវ = ..........................
- ប្រាក់ពន្ធបន្ថែម = ..........................

សរុប = ..........................

ជាអក្សរ " ........................................................................" ។

★★★

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

****

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — គំរូទី៤ -ក

នាយកដ្ឋានពន្ធដារ — ( អាថ្ងៃ )

សាខាពន្ធដារខេត្ត-ក្រុង............

លេខ...........................ពដ — ....................ថ្ងៃទី...............ខែ..........ឆ្នាំ..........

## លិខិតទារបំណុលពន្ធ

### ជំរាបមក

លោក-លោកស្រី..................................................................................................

អាស័យដ្ឋានផ្ទះលេខ............ផ្លូវ.............ឃុំសង្កាត់..............ស្រុក-ខ័ណ្ឌ...................

ខេត្ត-ក្រុង .........................ទូរស័ព្ទ...........................ប្រអប់សំបុត្រ...................

តាមការពិនិត្យស្ថានភាពគណនេយ្យពន្ធឃើញថា លោក-លោកស្រីនៅមិនទាន់បង់ពន្ធ :

* ប្រាក់ចំនួន ..............................................................................................

* ដែលជា ពន្ធលើដីធ្លីមិនបានប្រើប្រាស់សំរាប់ឆ្នាំ ..........................

ផ្អែកតាមបទប្បញ្ញត្តិនៃមាត្រា ១០៧ នៃច្បាប់ស្តីពីសារពើពន្ធ លោក-លោកស្រីមានរយៈពេលចំនួន ៣ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតនេះ សំរាប់ការអញ្ជើញមកបង់ប្រាក់ទាំងនេះនៅបេឡាអង្គភាពយើងខ្ញុំ ។ បើមិនបានបង់ប្រាក់ក្នុងរយៈពេលនេះទេ ចំនួនប្រាក់ដែលលោក-លោកស្រីត្រូវបង់នេះ នឹងត្រូវបូកពន្ធបន្ថែមពីលើ ១០ % និងការប្រាក់យឺតពេល ២% លើប្រាក់ពន្ធបង់យឺតយ៉ាវសំរាប់ខែនីមួយៗថែមទៀត ដូចមានចែងក្នុងមាត្រា ១៣២ នៃច្បាប់ស្តីពីសារពើពន្ធឆ្នាំ ១៩៩៧ ។

ចំណាំ

លេខរៀងខ្ទង់ប្រាក់ត្រូវបង់ ........................

កាលបរិច្ឆេទនៃការទទួលបន្ទុក ...................

ប្រធានសាខាពន្ធដារខេត្ត-ក្រុង

★★★

## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

****

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

នាយកដ្ឋានពន្ធដារ

សាខាពន្ធដារខេត្ត-ក្រុង.............

ឧបសម្ព័ន្ធទី៤-២

លេខ.............................ពដ

.....................ថ្ងៃទី ..........ខែ..........ឆ្នាំ..........

## លិខិតទារបំណុលពន្ធ

## ជំពាបមក

លោក-លោកស្រី.............................................................................................

អាស័យដ្ឋានផ្ទះលេខ...........ផ្លូវ.............ប៉ុស្តិ៍.............ស្រុក-ខណ្ឌ.................

ខេត្ត-ក្រុង ..........................ទូរស័ព្ទ...........................ប្រអប់សំបុត្រ...................

តាមការពិនិត្យស្ថានភាពសារពើពន្ធពបញ្ជាក់ថា លោក-លោកស្រីនៅមិនទាន់បង់ពន្ធ :

* ប្រាក់ចំនួន ........................................................................................

* ដែលជា ពន្ធលើដីធ្លីមិនបានប្រើប្រាស់សំរាប់ឆ្នាំ ........................

ផ្អែកតាមបទប្បញ្ញត្តិនៃមាត្រា ១០៧ នៃច្បាប់ស្តីពីសារពើពន្ធ លោក-លោកស្រីមានរយៈពេលចំនួន ៣០ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតនេះ សំរាប់ការអញ្ជើញមកបង់ប្រាក់ទាំងនេះនៅបេឡាអង្គភាពយើងខ្ញុំ ។ បើមិនបានបង់ប្រាក់ក្នុងរយៈពេលនេះទេ ចំនួនប្រាក់ដែលលោក-លោកស្រីត្រូវបង់នេះនឹងត្រូវបូកពន្ធបន្ថែមពីលើ ១០ % និងការប្រាក់យឺតយ៉ាវ ២% លើប្រាក់ពន្ធបង់យឺតយ៉ាវសំរាប់ខែនីមួយៗថែមទៀត ដូចមានចែងក្នុងមាត្រា ១៣២ នៃច្បាប់ស្តីពីសារពើពន្ធឆ្នាំ ១៩៩៧ ។

ចំណាំ

លេខរៀងខ្ទង់ប្រាក់ត្រូវបង់ ........................

កាលបរិច្ឆេទនៃការទទួលបន្ទុក ...................

ប្រធានសាខាពន្ធដារខេត្ត-ក្រុង

★★★

## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

****

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

នាយកដ្ឋានពន្ធដារ

សាខាពន្ធដារខេត្ត-ក្រុង.............

លេខ.................................ពដ

គំរូទី៥

.........................ថ្ងៃទី ..........ខែ..........ឆ្នាំ..........

## លិខិតរំលឹកការទារបំណុលពន្ធ

### ជំរាបមក

លោក-លោកស្រី..............................................................................................

អាសយដ្ឋានផ្ទះលេខ...........ផ្លូវ.............ឃុំ/សង្កាត់.............ស្រុក-ខណ្ឌ..................

ខេត្ត-ក្រុង .........................ទូរស័ព្ទ..........................ប្រអប់សំបុត្រ...................

ក្រោយពីបានពិនិត្យស្ថានភាពការពើពន្ធឃើញថា លោក-លោកស្រីនៅមិនទាន់បង់ពន្ធ :

* ប្រាក់ចំនួន ...........................................................................................

* ដែលជា ពន្ធលើដីធ្លីមិនបានប្រើប្រាស់សំរាប់ឆ្នាំ ..........................

យើងខ្ញុំបានផ្ញើជូនលោក-លោកស្រីរួចមកហើយនូវលិខិតទារបំណុលពន្ធលេខ ........... ចុះថ្ងៃទី........... ខែ............ឆ្នាំ............. ដោយទុកពេល៣០ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតទារបំណុលពន្ធ សំរាប់លោក-លោកស្រីអញ្ជើញមកបង់ប្រាក់តាមចំនួនខាងលើនេះ ។

ជាថ្មីម្តងទៀត យើងខ្ញុំទុករយៈពេល ១៥ថ្ងៃ គិតចាប់ពីថ្ងៃទទួលលិខិតរំលឹកការទារបំណុលពន្ធនេះសំរាប់លោក-លោកស្រី អញ្ជើញមកបង់ប្រាក់ពន្ធតាមចំនួនខាងលើ ដោយបូកប្រាក់ពន្ធបន្ថែម ១០ % និងការប្រាក់យឺតយ៉ាវ ២ % លើប្រាក់ពន្ធបង់យឺតយ៉ាវសំរាប់ខែនីមួយៗចំនួន : ............................ ។

សរុបប្រាក់ពន្ធទាំងអស់ដែលត្រូវបង់ចំនួន : .....................................

បើនៅតែមិនអញ្ជើញមកបង់ប្រាក់ក្នុងរយៈពេល ១៥ថ្ងៃដែលទុកជូនខាងលើនេះទៀត លោក-លោកស្រីនឹងត្រូវបូកបន្ថែម ២៥ % និង ការប្រាក់យឺតយ៉ាវ ២ % នៃចំនួនប្រាក់ពន្ធបង់យឺតយ៉ាវសំរាប់ខែនីមួយៗ ដោយគិតរហូតដល់ថ្ងៃដែល លោក-លោកស្រីបានមកទូទាត់ប្រាក់ពន្ធព្រមទាំងទោសទណ្ឌខាងលើនេះ និង លោកនឹងមានការរឹបអូសទ្រព្យសម្បត្តិរបស់ លោក-លោកស្រីទៀតផង ដូចមានចែងនៅមាត្រា ១១១ នៃច្បាប់ស្តីពីសារពើពន្ធ ។

**ចំណាំ**

លេខរៀងខ្ទង់ប្រាក់ត្រូវបង់ .......................

កាលបរិច្ឆេទនៃការទទួលបន្ទុក ...................

ប្រធានសាខាពន្ធដារខេត្ត-ក្រុង

★★★

# ដកស្រង់ចេញពីច្បាប់
## ស្តីពី
## សារពើពន្ធ

**មាត្រា ១១១ : ការរឹបអូស**

ការរឹបអូសទ្រព្យសម្បត្តិអ្នកជាប់ពន្ធ ត្រូវបានកំណត់ ដូចតទៅ :

១-ប្រសិនបើអ្នកជាប់ពន្ធមិនបានបង់បំណុលពន្ធក្នុងរយៈពេល ១៥ថ្ងៃ ក្រោយពីបានទទួលលិខិតជូនដំណឹងលើកការទារបំណុលពន្ធ រដ្ឋបាលសារពើពន្ធអាចរឹបអូសទ្រព្យសម្បត្តិរបស់អ្នកជា ដើម្បីទូទាត់បំណុលពន្ធព្រមទាំងសោហ៊ុយចំណាយក្នុងការប្រមូលពន្ធនោះ ។ សម្រាប់គោលដៅនៃច្បាប់នេះ ពាក្យ " ការរឹបអូស " សំដៅការរឹបអូសតាមគ្រប់មធ្យោបាយនិងការលក់ទ្រព្យសម្បត្តិអ្នកជាប់ពន្ធដោយរដ្ឋបាលសារពើពន្ធ តែមិនត្រូវរឹបអូសទ្រព្យសម្បត្តិឲ្យហួសពីបំណុលពន្ធនិងចំណាយក្នុងការប្រមូលពន្ធឡើយ ។

២-បុគ្គលដែលមានភារៈកាន់កាប់និងគ្រប់គ្រងទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ ដែលត្រូវរដ្ឋបាលសារពើពន្ធរឹបអូសដូចក្នុងកថាខណ្ឌ១ នៃមាត្រានេះ មិនអាចប្រគល់ទ្រព្យសម្បត្តិនោះទៅឲ្យអ្នកជាប់ពន្ធវិញ ឬក៏យកទ្រព្យសម្បត្តិនោះ ទៅធ្វើការទូទាត់ផ្សេងៗបានទេ លើកលែងតែការទូទាត់ដែលរដ្ឋបាលសារពើពន្ធបានអនុញ្ញាត ។

៣-រដ្ឋបាលសារពើពន្ធអាចអនុវត្តការរឹបអូសទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ ដែលកាន់កាប់និងគ្រប់គ្រងដោយបុគ្គលដទៃទៀត យ៉ាងតិចៗ ១៥ថ្ងៃក្រោយពេលជូនដំណឹងដល់អ្នកកាន់និងគ្រប់គ្រងទ្រព្យសម្បត្តិនោះ ។

៤-បុគ្គលកាន់កាប់និងគ្រប់គ្រងលើទ្រព្យសម្បត្តិដែលត្រូវរឹបអូស ត្រូវប្រគល់ទ្រព្យសម្បត្តិនោះ ឬ ក៏បង់ប្រាក់ពន្ធប្រាក់ពន្ធបន្ថែម ការប្រាក់និងសោហ៊ុយចំណាយក្នុងការប្រមូលពន្ធជូនរដ្ឋបាលសារពើពន្ធ លើកលែងតែតែលើទ្រព្យសម្បត្តិណាមួយដែលស្ថិតនៅក្នុងដំណើរការចំរុះបញ្ជីរណោះរបស់សកម្មភាពអាជីវកម្ម ។

៥-បុគ្គលដែលមិនបានប្រគល់ទ្រព្យសម្បត្តិ ដូចមានចែងក្នុងកថាខណ្ឌ៤ នៃមាត្រានេះ ត្រូវទទួលខុសត្រូវលើចំនួនទឹកប្រាក់នៃតម្លៃទ្រព្យសម្បត្តិនោះ ប៉ុន្តែមិនលើសពីចំនួនទឹកប្រាក់ដែលជាកម្មវត្ថុនៃការរឹបអូសនោះទេ ។

៦-បុគ្គលណាដែលបានប្រតិបត្តិការតាមការតម្រូវក្នុងកថាខណ្ឌ២ និង កថាខណ្ឌ៤ នៃមាត្រានេះ ត្រូវបានរួចផុតអំពីការទទួលខុសត្រូវចំពោះអ្នកជាប់ពន្ធ ឬ គតិយជន លើទ្រព្យសម្បត្តិ ប្រាក់ពន្ធ ឬ កាតព្វកិច្ចផ្សេងទៀត ដែលបានប្រគល់ជូនទៅរដ្ឋបាលសារពើពន្ធ ។

៧-ប្រសិនបើរដ្ឋបាលសារពើពន្ធមានមូលដ្ឋានត្រឹមត្រូវជឿជាក់ថា ការប្រមូលពន្ធអាចមានឧបសគ្គរដ្ឋបាលសារពើពន្ធអាចទាមទារឲ្យអ្នកជាប់បង់ពន្ធភ្លាម ហើយបើអ្នកជាប់ពន្ធមិនបានបំពេញតាមការទាមទារនេះទេ អាចរឹបអូសទ្រព្យសម្បត្តិអ្នកជាប់ពន្ធភ្លាម ។

៨-ទ្រព្យសម្បត្តិផ្ទាល់ខ្លួន ដូចមានចែងក្នុងអនុក្រឹត្យ ត្រូវបានរួចផុតពីការរឹបអូស ។

៩-ការលក់ទ្រព្យសម្បត្តិរឹបអូសត្រូវធ្វើឡើងតាមការដាក់ថ្លៃដេញថ្លៃ ។ សោហ៊ុយចំណាយផ្សេងៗក្នុងការលក់ទ្រព្យសម្បត្តិ គឺជាបន្ទុករបស់អ្នកជាប់ពន្ធ ។

★★★

## ៣-ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

## ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ ធ្នូ ឆ្នាំ ១៩៩៩

### ប្រកាសលេខ ៩៦៥ ឧក.ប្រក

****

### រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុ ព្រះចៅក្រុងកម្ពុជាធិបតី ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- ឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើត ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- បានឃើញលិខិតលេខ ១៩៥២/៩៩ ក.អ.ក. ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៩ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញលិខិតលេខ ៥១១ ប.ស្ថ.សប.ជ.ណ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ ១៩៩៩ របស់ក្រសួងបរិស្ថាន
- បានឃើញលិខិតលេខអនុញ្ញាតសាងសង់លេខ ២៩៥៨ ពអ.សរ ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩៨ របស់សាលាក្រុងភ្នំពេញ
- យោងពាក្យស្នើរបស់ក្រុមហ៊ុន អូសភីនធើ ហ្គាមេន មេនូហ្វេកជើរីង ( ខេមបូឌា ) លីមីធីត ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩

### សំរេច

ប្រការ ១ : អនុញ្ញាតឲ្យក្រុមហ៊ុន "អូសភីនធើ ហ្គាមេន មេនូហ្វេកជើរីង ( ខេមបូឌា ) លីមីធីត "OSPINTER GARMENT MANUFACTURING ( CAMBODIA ) LIMITED តំណាងដោយលោក HUI CHONG WAI MORLEY សញ្ជាតិ អង់គ្លេស ភេទប្រុស អាយុ ៣៥ ឆ្នាំ អាសយដ្ឋាន ៣ rd Floor Caltex House 258 Hennessy Road Wanchai HONGKONG កាន់លិខិតឆ្លងដែនលេខ

611182576 ចុះថ្ងៃទី11.07.94 បង្កើត " រោងចក្រកាត់ ដេរសំលៀកបំពាក់នាំចេញ " ដែលមានឈ្មោះថា "អ្លូសភីនធើ ប្អាមេន មេនូហ្វេកឈប័រីង ( ខេមបូឌា ) " មានទីតាំងស្ថិតនៅគីឡូម៉ែត្រលេខ ផ្លូវជាតិលេខ ២ ភូមិទួលរកា សង្កាត់ចាក់អង្រែក្រោម ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។

**ប្រការ ២ :** ក្នុងកិច្ចដំណើរការ ក្រុមហ៊ុនត្រូវរៀបចំអគារ និងគ្រឿងចក្រនៅតាមប្លង់ ដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ៣ :** រោងចក្រនេះត្រូវបានអនុញ្ញាតឲ្យ " កាត់-ដេរសំលៀកបំពាក់ " នៅតាមគំរូដែលតំកល់ទុក ហើយត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីស្ថានភាពផលិតកម្មរបស់រោងចក្រ ជូនក្រសួងឧស្សាហកម្ម រ៉ែ ថាមពល ។

**ប្រការ ៤ :** ក្រុមហ៊ុនត្រូវលើកបង្ហាញ " ផ្លាកឈ្មោះរោងចក្រ " របស់ខ្លួនជាអក្សរខ្មែរមានទំហំធំជាង និងនៅពីលើអក្សរផ្សេងទៀត នៅកន្លែងដែលងាយមើលឃើញនៅខាងមុខរោងចក្រ ។

**ប្រការ ៥ :** រាល់ការនាំចេញផលិតផលសំរេច ក្រុមហ៊ុនត្រូវសុំវិញ្ញាបនបត្របញ្ជាក់ផលិតកម្ម ពីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

**ប្រការ ៦ :** ក្រុមហ៊ុនត្រូវធានាសុវត្ថិភាពឧស្សាហកម្ម និង គុណភាពផលិតផល ព្រមទាំងត្រូវគោរពឲ្យបានម៉ឺងម៉ាត់ នូវច្បាប់ស្តីពីការងារ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងច្បាប់បទបញ្ញត្តិនានា ដែលពាក់ព័ន្ធនឹងផលិតកម្ម អាជីវកម្មរបស់ក្រុមហ៊ុន ។

**ប្រការ ៧ :** ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬ ល្មើសផ្ទុយនឹងប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

**ប្រការ ៨ :** ប្រធាននាយកដ្ឋានកិច្ចការឧស្សាហកម្ម ប្រធាននាយកដ្ឋានបច្ចេកទេស នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល រាជធានីភ្នំពេញ និង ប្រធានក្រុមហ៊ុន អ្លូសភីនធើ ប្អាមេន មេនូហ្វេកឈប័រីង ( ខេមបូឌា ) លីមីធីត ត្រូវអនុវត្តប្រកាសនេះតាមមុខការរៀងៗខ្លួន ។

**ប្រការ ៩ :** ប្រកាសនេះមានអនុភាព គតិយុត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.រដ្ឋមន្ត្រី
រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
**អ៊ិត ប្រាំង**

★★★

## ៨-ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

### ១- ប្រកាស

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ១៩៩៩

**ប្រកាសលេខ ២៦១២ អយក.ប្រក**

**ស្តីពីការបើក អនុវិទ្យាល័យ អូរបែកក្អម ជាឧបសម្ព័ន្ធអនុវិទ្យាល័យទឹកល្អក់ ស្ថិតក្នុងសង្កាត់អូរបែកក្អម ខណ្ឌទួលគោក រាជធានីភ្នំពេញ**

****

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និង កីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧៩៦/៥២ ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ១៩៩៦ ស្តីពីការប្រព័ន្ធអប់រំចំនេះទូទៅ ១២ ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អវ.ចបម ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ១៩៨៣ ស្តីពីការបើកសាលាមធ្យមសិក្សាកំរិត ១ កំរិត២
- យោងលើលិខិតលេខស្នើសុំរបស់ មន្ទីរអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញលេខ ៩៥១-៩៩ ណេស.អបេកភ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ដោយមានយោបល់ឯកភាពពីប្រតិភូរាជរដ្ឋាភិបាលប្រចាំរាជធានីភ្នំពេញ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

**សំរេច**

**ប្រការ ១ :** អនុញ្ញាតអោយបើកអនុវិទ្យាល័យដែលមានឈ្មោះថា : អនុវិទ្យាល័យ អូរបែកក្អម ជាឧបសម្ព័ន្ធអនុវិទ្យាល័យទឹកល្អក់ ចាប់ពីឆ្នាំសិក្សា ១៩៩៩-២០០០ តទៅ ។

**ប្រការ ២ :** អនុវិទ្យាល័យនេះត្រូវដឹកនាំដោយនាយករង ព្រមទាំងបុគ្គលិកផ្សេងៗ ចំនួនទៅតាមអង្គការលេខនៃអនុវិទ្យាល័យ ។

**ប្រការ ៣ :** នាយករងនៃវិទ្យាល័យខាងលើមានសិទ្ធិទទួលប្រាក់បំណាច់ការកិច្ចតាមគោលការណ៍របស់រដ្ឋ ។

**ប្រការ ៤ :** អគ្គនាយករដ្ឋបាល និង ហិរញ្ញវត្ថុ អគ្គនាយកអប់រំ ប្រធាននាយកដ្ឋានមធ្យមសិក្សាបច្ចេកទេសនិងវិជ្ជាជីវៈ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និង ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និង កីឡា និង ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានីភ្នំពេញ នាយកអនុវិទ្យាល័យទឹកល្អក់ និង នាយករងអនុវិទ្យាល័យអូរបែកក្អម មានភារកិច្ចរៀងៗខ្លួនអនុវត្តប្រកាសនេះ ។

ជ.រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
អ៊ឹម សិទ្ធី

★★★

# សេចក្តីសំរេច

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ១៩៩៩

## សេចក្តីសំរេចលេខ ០៧ អយក.ស.ស.រ
## ស្តីពីការទទួលស្គាល់សញ្ញាប័ត្រ
## របស់មណ្ឌលសិក្សាបច្ចេកទេសធនាគារ

****

- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ១៩៩២ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាវិជ្ជាជីវៈ
- បានឃើញប្រកាសលេខ ៦៩ អយក.ប្រក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតមណ្ឌលសិក្សាបច្ចេកទេសធនាគារ នៅរាជធានីភ្នំពេញ
- តាមសំណើរបស់មណ្ឌលសិក្សាបច្ចេកទេសធនាគារ
- តាមស្មារតីអង្គប្រជុំរបស់គណៈកម្មាធិការពិនិត្យវាយតម្លៃសញ្ញាប័ត្រ និង មេរៀនបញ្ចប់ការសិក្សានាថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៩

សំរេច

**ប្រការ ១ :** ប្រកាសនីយប័ត្រជាន់ខ្ពស់ ដែលចេញអោយដោយមណ្ឌលសិក្សាបច្ចេកទេសធនាគារ ត្រូវបានទទួលស្គាល់ថា ស្មើនឹងប្រកាសនីយប័ត្រជាន់ខ្ពស់ ដែលចេញអោយដោយគ្រឹះស្ថានឧត្តមសិក្សា និងត្រូវបានចុះបញ្ជីលេខាដោយថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ។

**ប្រការ ២ :** ក្រសួងអប់រំ យុវជន និងកីឡា ទទួលស្គាល់ប្រកាសនីយប័ត្រ និង ចុះបញ្ជីលេខាលើប្រកាសនីយប័ត្រ មណ្ឌលសិក្សាបច្ចេកទេសធនាគារលើមុខជំនាញណាដែលក្រសួងបាន អនុញ្ញាតអោយបង្កើត ។

**ប្រការ ៣ :** មណ្ឌលសិក្សាបច្ចេកទេសធនាគារ ត្រូវគោរពតាមលក្ខខណ្ឌ និង ការណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីធានាអនុវត្តការងារបណ្តុះបណ្តាលអោយមានគុណភាព ។ ក្នុងករណីដែលមណ្ឌលសិក្សាបច្ចេកទេសធនាគារ មិនគោរពលក្ខខណ្ឌ និង សេចក្តីណែនាំផ្សេងៗរបស់ក្រសួង ក្រសួងនឹងបញ្ឈប់ការទទួលស្គាល់ និង ការចុះបញ្ជីលេខាលើប្រកាសនីយប័ត្ររបស់មណ្ឌលសិក្សាបច្ចេកទេសធនាគារនេះ ។

**ប្រការ ៤ :** អគ្គនាយកដ្ឋានឧត្តមសិក្សាបច្ចេកទេស និង វិជ្ជាជីវៈ នាយកដ្ឋានឧត្តមសិក្សា អង្គភាពពាក់ព័ន្ធ និង មណ្ឌលសិក្សាបច្ចេកទេសធនាគារ មានភារកិច្ចរៀងខ្លួនៗ ដើម្បីអនុវត្ត និង ប្រតិបត្តិសេចក្តីសំរេចនេះ ។

**ប្រការ ៥ :** សេចក្តីសំរេចនេះ មានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ជ.រដ្ឋមន្ត្រីក្រសួង អប់រំ យុវជន និង កីឡា
រដ្ឋលេខាធិការ
ហត្ថលេខា និងត្រា
ម៉ុក ផន

***

## ៥-ទីស្តីការរដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

### ប្រកាស

រាជធានីភ្នំពេញ,ថ្ងៃទី១៥ ខែ ធ្នូ ឆ្នាំ ១៩៩៩

### ប្រកាសលេខ ២៦២ ប៩.ប្រក

### ស្តីពីការ រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៃប្រកាសលេខ ១៩០ ប៩.ប្រក ចុះថ្ងៃទី ១៧ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់មន្ទីរ ប.ទ.ខេត្ត-ក្រុង

****

### រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦៦/អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្ដីពីការរៀប... ការប្រព្រឹត្តទៅរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
- បានឃើញប្រកាសលេខ ១៩០ បទ.ប្រក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៩
- បានឃើញសេចក្ដីសំរេចរបស់អង្គប្រជុំរបស់ថ្នាក់ដឹកនាំក្រសួង ចុះថ្ងៃទី១៤-១២-៩៩
- បានឃើញការងារចាំបាច់របស់ក្រសួង

**សំរេច**

**ប្រការ ១ :** ត្រូវបានរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងគ្រង់ចំណុច ( គ ) ក្នុងប្រការ ៤ នៃប្រកាសលេខ ១៩០ បទ.ប្រក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ១៩៩៩ ស្ដីពីការិយាល័យទូរគមនាគមន៍ ដូចមាន ។

ខ្លឹមសារខាងក្រោមនេះ ÷

-ការិយាល័យទូរគមនាគមន៍មានតួនាទីភារកិច្ចទទួលបន្ទុកធ្វើសេវាកម្ម អាជីវកម្ម រៀបចំថែទាំ តម្លើង និង ជួសជុល គ្រប់មុខសញ្ញា នៃប្រព័ន្ធទូរគមនាគមន៍ដោយមានអនុប្រធានមន្ទីរ ប.ទ ខេត្ត មួយរូបទទួលបន្ទុក ។

ការិយាល័យទូរគមនាគមន៍ មានផ្នែកចំនួន ៣ ស្ថិតនៅក្រោម ឱវាទ :

១-ផ្នែក ប្រតិបត្តិ-ថែទាំ

២-ផ្នែក បណ្ដាញខាងក្រៅ

៣-ផ្នែក អាជីវកម្ម

**ប្រការ ២ :** ក.ផ្នែក ប្រតិបត្តិ-ថែទាំ មានតួនាទីទទួលបន្ទុកថែរក្សាបន្ទុក " **SWITCH** " ត្រួតពិនិត្យ " **Alarm Hard Wares** " ការតភ្ជាប់បណ្ដាញនៅ **MDF** ទៅតាមបណ្ដាញខ្សែខាងក្រៅ ថែរក្សាដំណើរការរបស់ **Rectifier Block** ទំនាក់ទំនងជាមួយ " Main Switch " នៅភ្នំពេញ ដើម្បីតភ្ជាប់បណ្ដាញថ្មី និងបណ្ដាញរអាក់រអួលផ្នែក " **Software** " ផ្សេងៗ ផ្ដល់ផ្ដង់ថាមពលអគ្គីនីជាប្រចាំ និងធ្វើរបាយការណ៍ជាប្រចាំថ្ងៃអំពីស្ថានភាពរបស់ " **SWITCH** " ។

-ផ្នែកប្រតិបត្តិ ថែទាំ មានក្រុមចំនួន ៣ ក្រោមឱវាទគឺ :

១-ក្រុមទូរស័ព្ទ និង វិភាគផ្លាន

២-ក្រុមបណ្តាញ ស៊ីញ៉ាល់ - បរិក្ខារបណ្តាញស៊ីញ៉ាល់

៣-ក្រុមថែទាំជួសជុលបណ្តាញកាប្លិ៍អុបទិក

ខ-ផ្នែកបណ្តាញខាងក្រៅមានតួនាទី ទទួលបន្ទុក ស្ថាបនាទូរស័ព្ទ ទូរសារ បម្រើជូនអតិថិជន សិក្សាប្លង់ រៀបចំប្លង់សំរាប់ស្ថាបនាទូរស័ព្ទថ្មី ប្រមូល តាមដានរាល់ការអភិវឌ្ឍន៍ បណ្តាញកាប្លិ៍ ផ្សព្វផ្សាយ និង បំពាក់បំប៉នបច្ចេកវិទ្យាថ្មី ថែទាំ និងជួសជុលបណ្តាញកាប្លិ៍ទូរស័ព្ទ គ្រប់គ្រង និងបែងចែក បណ្តាញជូនអតិថិជន សិក្សាផែនការពង្រីកបណ្តាញថ្មីក្នុងខេត្ត ទទួលពត៌មានទូរស័ព្ទខូច និងបែងចែក ប័ណ្ណជួសជុល ដោះស្រាយរាល់បាតុភាពអសកម្មផ្សេងៗដែលកើតមានដោយសារការបណ្តាញទំនាក់ទំនង ជាមួយមជ្ឈមណ្ឌលពាក់ព័ន្ធ ដោះស្រាយរាល់ការរំខានក្នុងការស្ថាបនា សហការជិតស្និទ្ធជាមួយអង្គភាពពាក់ព័ន្ធ និងបណ្តាញកាប្លិ៍ក្រោមដី ឬ អាកាស ។

ផ្នែកបណ្តាញខាងក្រៅមានក្រុមចំនួន ២ ក្រោមឱវាទគឺ :

១-ក្រុមថែទាំ និង ពង្រីកបណ្តាញខាងក្រៅ

២-ក្រុមស្ថាបនា និងជួសជុលទូរស័ព្ទ

គ-ផ្នែក អាជីវកម្មមានតួនាទីទទួលបន្ទុកធ្វើសេវាកម្ម អាជីវកម្មរៀបចំពិនិត្យរាល់ បណ្តាឯកសារ ដែលទាក់ទង នឹងការស្ថាបនាទូរស័ព្ទ ទូរសារ ទូរពុម្ព រៀបចំបទដ្ឋានផ្សេងៗដែលពាក់ព័ន្ធនឹងការងារ អាជីវកម្ម ។

ផ្នែកអាជីវកម្មមានក្រុមចំនួន ៣ ក្រោមឱវាទគឺ :

១-ក្រុមផ្តល់អាជ្ញាប័ណ្ណវិទ្យុ

២-ក្រុមរៀបចំឯកសារស្ថាបនាទូរស័ព្ទ

៣-ក្រុមសិក្សាទីផ្សារ

ប្រការ ៣ : ការរៀបចំរចនាសម្ព័ន្ធ គ្រប់គ្រងដូចមានក្នុងប្រការ ១ ខាងលើនេះ អនុវត្តន៍ សំរាប់ក្នុងក្របខ័ណ្ឌ នៃ បណ្តាមន្ទីរប.ទ ខេត្ត តែ ៥ ប៉ុណ្ណោះ គឺ មន្ទីរ ប.ទ ខេត្ត បន្ទាយមានជ័យខេត្តបាត់ដំបង, ខេត្តពោធិសាត់ , ខេត្តកំពង់ឆ្នាំង និងខេត្តស្វាយរៀង ។

ប្រការ ៤ : ប្រកាសនេះ និង មានការកែប្រែ បើមានការចាំបាច់ ។

ប្រការ ៥ : អគ្គនាយកដ្ឋាន ខុទ្ទកាល័យ អធិការដ្ឋាន គ្រប់នាយកដ្ឋានចំណុះក្រសួងរៀបរែសណើយ៍ និងទូរគមនាគមន៍ គ្រប់មន្ទីររៀបរែសណើយ៍ និងទូរគមនាគមន៍ខេត្ត-ក្រុង និង ជួចប្រការ ៣ ខាងលើត្រូវសាយការអនុវត្តន៍ តាមខ្លឹមសារ នៃប្រកាសនេះ ។

ប្រការ ៦ : ប្រកាសនេះមានប្រសិទ្ធភាព ចាប់ពីចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

សូ ឃុន

★★★